**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ៖ សហព័ទ្ធ និងអនីតិសង្វាសជន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **សេង ស៊ីម៉េង**

**ប៉ែន គ្លីនគុន**

សាស្ត្រាចារ្យណែនាំ

លោក **ព្រុំ រិទ្ធី**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ៖ សហព័ទ្ធ និងអនីតិសង្វាសជន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **សេង ស៊ីម៉េង**
**ប៉ែន គ្លីនតុន**

សាស្ត្រាចារ្យណែនាំ
លោក **ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ជាដំបូងយើងខ្ញុំឈ្មោះ **សេង ស៊ីម៉េង** និង **ម៉ែន គ្លីនតុន** ជានិស្សិត ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត ឆ្នាំទី៤ ជំនាន់ទី២១ ក្នុងឆ្នាំសិក្សា២០១៧-២០២១ សូមសម្តែងនូវកតញ្ញូ និងដឹងគុណដ៏ជ្រាលជ្រៅមិនអាចកាត់ថ្លៃបានដល់លោកអ្នកមានគុណទាំងបួន គឺលោកឪពុក **សេង ហ៊ីរ** និងអ្នកម្តាយ **ស៊ឹម ឆាង** និង លោកឪពុក **ម៉ែន ហ៊ាង** និងអ្នកម្តាយ **ស៊ាច ធីតា** ដែលបានផ្តល់នូវកំណើតដល់រូបយើងខ្ញុំ និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងបានផ្តល់នូវការស្នាក់នៅ និងការរៀនសូត្រតាំងពីថ្នាក់មត្តេយ្យនៅបឋមវ័យសិក្សារហូតមកដល់កម្រិតថ្នាក់បរិញ្ញាបត្រ ហើយបានរួមចំណែកក្នុងការផ្តល់នូវកម្លាំងចិត្ត ការអប់រំ ប្រៀនប្រដៅ និងព្រហ្មវិហារធម៌ពីសំណាក់បុព្វញាតិ និងសាខាញាតិ។ សេចក្តីដឹងគុណទាំងអស់នេះ ពិតជាធំធេងពុំអាចកាត់ថ្លៃបានឡើយសម្រាប់ជីវិតពួកយើងទាំងពីរ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំង សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច បានផ្តល់នូវកន្លែងបណ្តុះបណ្តាលចំណេះដឹង សមត្ថភាព ក៏ដូចជាការស្រាវជ្រាវ ក្នុងផ្នែកនីតិសាស្រ្តនេះ តាំងពីឆ្នាំទីមួយរហូតមកដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ប្រកបដោយភាពជោគជ័យ ផ្លែផ្កា និងសមិទ្ធផលចំណេះដឹងយ៉ាងគាប់ប្រសើរ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំគណៈគ្រប់គ្រង និង លោក លោកស្រីសាស្រ្តាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិស្រាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលលោក លោកស្រី បានធ្វើការផ្តល់នូវចំណេះដឹង ការអប់រំ និងសីលធម៌ដល់យើងខ្ញុំទាំងពីរក្នុងរយៈពេលជិត ៤ឆ្នាំនេះ។

លើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រង នៃបណ្ណាល័យនីតិសាស្រ្ត ដែលរៀបចំ គ្រប់គ្រងឯកសារច្បាប់ សៀវភៅមេរៀន ឯកសារស្រាវជ្រាវ ក៏ដូចជាជួយសម្រួលក្នុងការស្រាវជ្រាវតាក់តែងសារណារបស់យើងខ្ញុំ។

ពិសេសជាងនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់លោកសាស្រ្តាចារ្យ **ព្រុំ រិទ្ធី** ដែលជាសាស្រ្តាចារ្យណែនាំ និងដឹកនាំការសរសេរសារណារបស់យើងខ្ញុំ ដោយលោកបានខិតខំទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃ ក្នុងការផ្តល់នូវដំបូន្មាន គំនិត ចំណេះដឹង យោបល់ ការលើកទឹកចិត្ត និងការបង្ហាញផ្លូវដល់យើងខ្ញុំ ចាប់ពីថ្ងៃចាប់ផ្តើមសរសេរ រហូតដល់ទទួលបានស្នាដៃមួយនេះជាស្ថាពរ ដែលគុណទាំងនេះ គឺពិតជាមានតម្លៃវិសេសវិសាលឥតកាត់ថ្លៃបានមកលើយើងខ្ញុំ។

# អារម្ភកថា

យើងខ្ញុំឈ្មោះ **សេខ ស៊ីម៉េខ** និង **ម៉ែន គ្លីនតុន** ជានិស្សិត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី ២១ បានឆ្លងកាត់ការសិក្សា និងការបណ្តុះបណ្តាលក្នុងថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ អស់រយៈពេល ៤ឆ្នាំមកហើយ។ តាមរយៈការសិក្សាអស់ពេល ៤ឆ្នាំនេះ ឃើញថាការសិក្សាបរិញ្ញាបត្រ នីតិសាស្ត្រ ផ្នែកនីតិសាស្ត្រនេះ ពិតជាផ្តល់នូវសារៈសំខាន់យ៉ាងខ្លាំងសម្រាប់យើងខ្ញុំក្នុងនាមជាយុវជនជំនាន់ក្រោយ។ ជាក់ស្តែង យើងខ្ញុំទទួលបាននូវចំណេះដឹង និងបទពិសោធន៍ជាច្រើនពីការសិក្សាកន្លងមកនេះ។ ទោះបីជាកាលៈទេសៈខ្លះ យើងខ្ញុំបានជួបប្រទះនូវឧបសគ្គ និងការលំបាកយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែព្យាយាមតស៊ូក្រេបយកចំណេះវិជ្ជា ដោយមិនព្រមបោះបង់នូវការសិក្សាដ៏គាប់ប្រសើរនេះឡើយ ក្នុងគោលបំណងមួយដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនេះឱ្យបានជោគជ័យជាស្ថាពរ។ ទន្ទឹមនឹងការបញ្ចប់បរិញ្ញាបត្រឱ្យបានជោគជ័យដែរនោះ យើងខ្ញុំក៏មានគោលបំណងក្នុងការបញ្ចប់ការសិក្សាដោយការសរសេរសារណាមួយដ៏សមប្រកប ដែលជាលទ្ធផល និងស្នាដៃដ៏សំខាន់មួយសម្រាប់យើងខ្ញុំបន្ទាប់ពីបានសិក្សាក្រេបយកចំណេះដឹងអស់រយៈពេល ៤ឆ្នាំកន្លងមកនេះ។

ដោយឡែក ដោយសារតែមានការឆ្លងកាត់ការសិក្សាកន្លងមកនូវមុខវិជ្ជាសំខាន់ៗជាច្រើនក្នុងបរិញ្ញាបត្រ នីតិសាស្ត្រ ផ្នែកនីតិសាស្ត្រនេះ យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើមុខវិជ្ជានីតិរដ្ឋប្បវេណី ព្រោះថាមុខវិជ្ជានេះ គឺជាមុខវិជ្ជាដែលសិក្សាទាក់ទងនឹងទំនាក់ទំនងឯកជន ហើយក៏ជាវិធានច្បាប់មួយដ៏សំខាន់ក្នុងចំណោមវិធានច្បាប់ផ្សេងៗទៀតសម្រាប់គ្រប់គ្រងសង្គម។ ដោយយើងខ្ញុំបានសិក្សាលើការកកើតអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ព្រមទាំងប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធដែលកើតឡើងដោយអាពាហ៍ពិពាហ៍នោះ យើងខ្ញុំក៏បានសាកល្បងសង្កេតទៅមើលស្ថានភាពផ្ទុយវិញ ពោលគឺអាពាហ៍ពិពាហ៍មិនតាមផ្លូវច្បាប់ ហើយជាលទ្ធផល វាបានផ្តល់នូវទស្សនៈទានមួយដ៏ប្រសើរសម្រាប់ការសិក្សាស្រាវជ្រាវ។ អាស្រ័យហេតុនេះហើយ ទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសយក ប្រធានបទមួយគឺ «**ការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ៖ សហព័ទ្ធ និងអនីតិសង្វាស**» មកធ្វើការសិក្សាស្រាវជ្រាវ។

មូលហេតុ ដែលយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងឡើងនោះ គឺដោយសារយើងខ្ញុំមានបំណងក្នុងការទទួលបាននូវបទពិសោធន៍ និងចំណេះដឹងកាន់តែស៊ីជម្រៅអំពីការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ ជាពិសេសក្នុងករណីជាសហព័ទ្ធ និងអនីតិសង្វាសជន ទោះបីជាប្រធានបទនេះត្រូវបានសិស្សច្បងជំនាន់មុនៗយកមកធ្វើការសរសេររួចក៏ដោយ។

ដោយហេតុថា ប្រធានបទ «**ការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ៖ សហព័ទ្ធ និងអនីតិសង្វាស**» មានភាពធំទូលាយ និងស្មុគស្មាញ ដូច្នេះយើងខ្ញុំសូមអភ័យទោសជាមុនប្រសិនបើមានភាពខ្វះខាតត្រង់ចំណុចណាមួយ

ដែលនាំឱ្យការស្រាវជ្រាវរបស់យើងខ្ញុំនៅមានកម្រិត។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែសង្ឃឹមថាការស្រាវជ្រាវមួយនេះនឹងអាចផ្តល់នូវចំណេះដឹងបន្ថែមបន្តិចបន្តួចដល់មជ្ឈដ្ឋានអ្នកសិក្សា។

យើងខ្ញុំសូមទទួលការរិះគន់ដោយស្តាបនាពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ បងៗ ប្អូនៗ មិត្តនិស្សិតទាំងអស់ដែលបានអានស្នាដៃមួយនេះ និងរីករាយទទួលនូវរាល់កំហុសដែលកើតមានឡើងដោយអចេតនារបស់យើងខ្ញុំ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ**

**១.១- ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ** ........ ៤

១.១.១- ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ........ ៥

១.១.១.១- អត្ថប្រយោជន៍នៃប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា........៥

១.១.១.២- អំពីការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ........៩

១.១.១.៣- អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........១៤

**១.១.២- ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់** ........១៥

១.១.២.១- ទ្រព្យសម្បត្តិសកម្មរបស់សហព័ទ្ធ........ ១៥

១.១.២.២- ទ្រព្យសម្បត្តិអកម្មរបស់សហព័ទ្ធ ........ ១៨

**១.២- ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិសន្ធានជន** ........២០

១.២.១- ការអនុវត្តតាមរបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលកំណត់ដោយច្បាប់........២០

១.២.២- ការអនុវត្តតាមបញ្ញត្តិអំពីកម្មសិទ្ធិអវិភាគ ........ ២១

១.២.២.១- សញ្ញាណនៃកម្មសិទ្ធិអវិភាគ........២១

១.២.២.២- ការប្រើប្រាស់ ថែទាំ និងគ្រប់គ្រងវត្ថុនៃកម្មសិទ្ធិអវិភាគ ........២២

១.២.២.៣- ការចាត់ចែងវត្ថុនៃកម្មសិទ្ធិអវិភាគ ........២៣

១.២.២.៤- បន្ទុករបស់ម្ចាស់កម្មសិទ្ធិអវិភាគចំពោះវត្ថុនៃកម្មសិទ្ធិអវិភាគ........២៤

**ជំពូកទី២**

**ការបញ្ចប់នៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ**

**២.១- ការបញ្ចប់នៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ** ........២៥

២.១.១- ការលែងលះ........២៥

២.១.១.១- ប្រភេទនៃការលែងលះ ........................................................................... ២៥
២.១.១.២- ការបែងចែកទ្រព្យសម្បត្តិ ........................................................................... ២៦
២.១.២- មរណភាពនិងការប្រកាសអំពីការបាត់ខ្លួន ........................................................ ២៧
២.១.២.១- អំពីមរណភាព និងការប្រកាសអំពីការបាត់ខ្លួន ................................................ ២៧
២.១.២.២- អំពីការបែងចែកទ្រព្យសម្បត្តិ ..................................................................... ២៨
២.២- ការបញ្ចប់នៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិសង្វាសជន ........................................ ២៨
២.២.១- ការបង្កើតអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ .............................................................. ២៨
២.២.១.១- អំពីការបង្កើតអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ....................................................... ២៨
២.២.១.២- អំពីអានុភាពនៃការរំលាយអនីតិសង្វាសតាមរយៈអាពាហ៍ពិពាហ៍ ............................ ២៨
២.២.២- ការព្រមព្រៀងគ្នាបញ្ចប់ទំនាក់ទំនងអនីតិសង្វាស ................................................ ២៩
២.២.២.១- អំពីការព្រមព្រៀងគ្នាបញ្ចប់ទំនាក់ទំនងអនីតិសង្វាស ............................................ ២៩
២.២.២.២- អំពីអានុភាពនៃការរំលាយអនីតិសង្វាសដោយការព្រមព្រៀងគ្នា .............................. ២៩
២.២.៣- មរណភាពនិងការប្រកាសអំពីការបាត់ខ្លួន ........................................................ ៣២
២.២.៣.១- អំពីការមរណភាពនិងការប្រកាសអំពីការបាត់ខ្លួន ................................................ ៣២
២.២.៣.២- អំពីអានុភាពនៃការរំលាយអនីតិសង្វាសដោយមរណភាព ...................................... ៣២
**សេចក្តីសន្និដ្ឋាន** ....................................................................................... ៣៣
**អនុសាសន៍** ............................................................................................. ៣៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១- លំនាំបញ្ហា

ក្នុងសង្គមកម្ពុជា មនុស្សគ្រប់រូបតែងតែប្រកាន់ខ្ជាប់នូវប្រពៃណី ទំនៀមទម្លាប់ និងសាសនានៅក្នុងប្រតិបត្តិការជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន។ ក្នុងនោះដែរ ការរៀបចំអាពាហ៍ពិពាហ៍រវាងជនប្រុស-ស្រី ក៏មានការចូលរួមពីធាតុចូលទាំងបីខាងលើនេះដែរ ដែលការអនុវត្តនេះត្រូវបានប្រកាន់យកតាំងពីបុរាណកាលមក។ ជាមួយគ្នានឹងការមកដល់នៃអាណាព្យាបាលបារាំង កម្ពុជាបានទទួលយកនូវបទពិសោធន៍ថ្មីនៃការធ្វើទំនើបកម្មក្នុងវិស័យច្បាប់របស់ខ្លួន ដោយការប្រកាន់យកក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ សម្រាប់ការគ្រប់គ្រងលើទំនាក់ទំនងឯកជននិយាយជារួម និងលើទំនាក់ទំនងគ្រួសារនិយាយដោយឡែក។ ប៉ុន្តែ ការផ្លាស់ប្តូររបបនយោបាយក្នុងសង្គមកម្ពុជាបានបណ្តាលឱ្យមានការប្រែប្រួលលើរបបគតិយុត្តទាំងនេះ រហូតទាល់តែដល់ឆ្នាំ១៩៨៩ ទើបកម្ពុជាមានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រងលើទំនាក់ទំនងគ្រួសារសារជាថ្មី ពោលគឺច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩។ លើសពីនេះ កម្ពុជាមានលិខិតបទដ្ឋានគតិយុត្តថ្មីមួយទៀតដែលគ្រប់គ្រងលើទំនាក់ទំនងឯកជន ហើយបានចូលជាធរមាននៅឆ្នាំ២០០៧និងចាប់ផ្តើមអនុវត្តនៅឆ្នាំ២០១១ គឺក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ជាមួយគ្នានេះ ភាពប្រទាំងប្រទិសគ្នារវាងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់និងអាពាហ៍ពិពាហ៍មិនតាមផ្លូវច្បាប់បានចោទជាបញ្ហាឡើង។ ដើម្បីធ្វើការពិភាក្សាលើបញ្ហាខាងលើឱ្យបានស៊ីជម្រៅ និយមន័យនៃពាក្យ «**អាពាហ៍ពិពាហ៍**» គួរផ្តល់ជាមុនសិន។ **អាពាហ៍ពិពាហ៍** សំដៅលើកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថារួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។[1] ក្នុងករណី ក្រោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ នោះប្តី ឬប្រពន្ធ ឬទាំងប្តីទាំងប្រពន្ធនឹងទទួលបានឋានៈជា **សហព័ទ្ធ**។[2] ផ្ទុយទៅវិញ ករណីស្ថានភាពរបស់បុរស និងនារីដែលរួមរស់នៅជាមួយគ្នាដូចប្តីប្រពន្ធមានខាន់ស្លា ប៉ុន្តែឥតមានចុះសំបុត្រអាពាហ៍ពិពាហ៍ទេនោះ គឺជា**អនីតិសង្វាស**[3] ហើយជនដែលរួមរស់នៅជាមួយគ្នាដូចជាប្តីប្រពន្ធដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់នោះ ត្រូវបានហៅថា **អនីតិសង្វាសជន**។[4] ដូចនេះ ប្តីប្រពន្ធអាចសំដៅទៅលើស្ថានភាពពីរ គឺសហព័ទ្ធ (ប្តីប្រពន្ធរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់) និង អនីតិសង្វាសជន (ប្តីប្រពន្ធរៀបអាពាហ៍ពិពាហ៍មិនតាមផ្លូវច្បាប់)។ លើសពីនេះ ទំនាក់ទំនងគតិយុត្តរវាងប្តីប្រពន្ធនឹងប្រែប្រួលទៅតាមស្ថានភាពណាមួយក្នុងចំណោមស្ថានភាពទាំងពីរខាងលើ ជាពិសេស

---

[1] ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦, មាត្រា៣ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ៨ ធ្នូ ២០០៧, សន្ទានុក្រម, ទំព័រ២២។

[3] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០០៥, *សន្ទានុក្រមបារាំង-ខ្មែរនៃពាក្យច្បាប់*, ទំព័រ៧៩។

[4] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ២០១៧, *សៀវភៅជំនួយស្មារតី នីតិវិធីព្រហ្មទណ្ឌ និង នីតិគ្រួសារ*, ទំព័រ៤៥០។

ទៅលើទំនាក់ទំនងបុគ្គល និងទំនាក់ទំនងទ្រព្យសម្បត្តិ។ យ៉ាងណាមិញ ការសិក្សាស្រាវជ្រាវនេះនឹងសិក្សាលើទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធតែប៉ុណ្ណោះ។

## ២- ចំណោទបញ្ហា នៃការស្រាវជ្រាវ

នៅក្នុងទំនាក់ទំនងប្តីប្រពន្ធ គឺផ្តោតសំខាន់លើទំនាក់ទំនងបុគ្គល និង ទំនាក់ទំនងទ្រព្យសម្បត្តិ ប៉ុន្តែដោយសារការសិក្សាស្រាវជ្រាវនេះផ្តោតតែលើទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ដែលសំដៅលើការគ្រប់គ្រងទ្រព្យសម្បត្តិ ដូចនេះ តើប្តីប្រពន្ធធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិយ៉ាងដូចម្តេច? ក្នុងនោះ តើសហព័ទ្ធធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនយ៉ាងដូចម្តេច? ហើយ តើអនីតិសង្វាសជនធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនយ៉ាងដូចម្តេចដែរ?

## ៣- គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវពីប្រធានបទ «**ការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ៖ សហព័ទ្ធ និងអនីតិសង្វាស**» នេះ មានបំណងសិក្សាលើរបៀបនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ដែលផ្តោតសំខាន់ក្នុងករណីស្ថានភាពប្តីប្រពន្ធជាសហព័ទ្ធ ឬ ជាអនីតិសង្វាសជន។ ហើយឈានទៅបង្ហាញពីគុណសម្បត្តិនិងគុណវិបត្តិនៃការគ្រប់គ្រងក្នុងស្ថានភាពទាំងពីរនោះ ដើម្បីជាគំនិតដល់សាធារណជនក្នុងការពិចារណាជ្រើសរើសយកការគ្រប់គ្រងណាមួយឱ្យសមស្របទៅស្ថានភាពតម្រូវដោយជៀសវាងការកើតឡើងនូវព្យសនកម្មនាពេលអនាគត។

## ៤- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដូចបានបញ្ជាក់ខាងលើ ការសិក្សាស្រាវជ្រាវពីប្រធានបទ «**ការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ៖ សហព័ទ្ធ និងអនីតិសង្វាស**» នេះ នឹងសិក្សាលើតែទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធប៉ុណ្ណោះ ពោលគឺការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ដែលចាប់ពីមូលហេតុនាំឱ្យមានការគ្រប់គ្រង បែបបទក្នុងការគ្រប់គ្រង និងចុងក្រោយគឺការបញ្ចប់នៃការគ្រប់គ្រងនោះ។ សូមបញ្ជាក់ផងដែរថា ការសិក្សានេះពុំមានការសិក្សាលើទំនាក់ទំនងបុគ្គល និងរបបស្តីពីសន្តតិកម្មឡើយ។

## ៥- សារៈសំខាន់ នៃការស្រាវជ្រាវ

ប្រធានបទនៃសារណាស្តីពី «**ការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ៖ សហព័ទ្ធ និងអនីតិសង្វាស**» នេះ នឹងអាចផ្តល់សារប្រយោជន៍យ៉ាងច្រើនទាក់ទងនឹងការយល់ដឹងឱ្យកាន់តែច្បាស់អំពីបែបបទនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ពោលគឺចំណេះដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ និងអនីតិសង្វាសជន ដែលរួមមាន ដំបូងគឺសញ្ញាណនៃទ្រព្យសម្បត្តិរបស់សហព័ទ្ធ និងអនីតិសង្វាសជន បន្ទាប់មកគឺរបៀបនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ និងអនីតិសង្វាសជន ដែលមានការប្រើប្រាស់ ការចាត់ចែង ជាអាទិ៍ និងចុងក្រោយគឺការបញ្ចប់នៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ និងអនីតិសង្វាស។ ដូចនេះ សរុបជារួមមក គឺ

ទទួលបានចំណេះដឹងពីការកកើតនៃទ្រព្យសម្បត្តិ របៀបនៃការគ្រប់គ្រងទ្រព្យសម្បត្តិនោះ និងការបែងចែកទ្រព្យសម្បត្តិនោះផងដែរ។

## ៦- រចនាសម្ព័ន្ធ នៃការស្រាវជ្រាវ

ទាក់ទងទៅនឹងប្រធានបទ «**ការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ៖ សហព័ទ្ធ និងអនីតិសង្វាស**» នៅក្នុងចំណុចបន្ទាប់ នឹងធ្វើការបកស្រាយនូវចំណុចសំខាន់ទាក់ទងនឹង៖

- **ជំពូកទី១ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ**
- **ជំពូកទី២ ការបញ្ចប់នៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ**

# ជំពូកទី១

# ការគ្រប់គ្រងទ្រព្យសម្បត្តិ
# របស់ប្តីប្រពន្ធ

# ជំពូកទី១

# ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ

ដូចបានបញ្ជាក់ខាងលើនេះ កម្ពុជាមានក្រមរដ្ឋប្បវេណីជាលើកដំបូងនៅឆ្នាំ ១៩២០ (បានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០) សម្រាប់គ្រប់គ្រងលើទំនាក់ទំនងឯកជនក្នុងសង្គម។ ក្នុងនោះ បញ្ញត្តិស្ដីពីគ្រួសារបានមានអត្ថិភាព ដើម្បីគ្រប់គ្រងលើទំនាក់ទំនងញាតិ និងទ្រព្យសម្បត្តិនៅក្នុងគ្រួសារ ជាពិសេសបានកំណត់ឱ្យមានបញ្ញត្តិស្ដីពីអាពាហ៍ពិពាហ៍ដែលបង្កើតឱ្យមាន ជាប្ដីប្រពន្ធក្នុងអាពាហ៍ពិពាហ៍ស្របច្បាប់ ឬ សហព័ទ្ធ ហើយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួន គឺបានអនុវត្តតាមគោលការណ៍ទ្រព្យរួម និងទ្រព្យដោយឡែក។[5] យ៉ាងណាមិញ ទោះនៅក្នុងសម័យកាលនោះមានច្បាប់គ្រប់គ្រងក៏ដោយក្ដី ដោយសារតែពុំអាច ឬ មិនចង់បំពេញនូវលក្ខខណ្ឌនៃអាពាហ៍ពិពាហ៍ស្របច្បាប់ នោះស្ថានភាពដែលប្ដីប្រពន្ធរស់នៅក្នុងអាពាហ៍ពិពាហ៍មិនស្របច្បាប់ ឬ អនីតិសង្វាស ក៏អាចកើតមានឡើងផងដែរ។ រហូតដល់ឆ្នាំ ១៩៨៩ ទើបកម្ពុជាមានច្បាប់គ្រប់គ្រងលើគ្រួសារ និងអាពាហ៍ពិពាហ៍ ដែលក្នុងនោះ បានកំណត់ឱ្យមានសហព័ទ្ធ ឬ ប្ដីប្រពន្ធក្នុងអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយជាមួយគ្នា ក៏បានកំណត់ពីបញ្ញត្តិក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធផងដែរ ដែលអនុវត្តតាមគោលការណ៍ទ្រព្យរួម និងទ្រព្យដោយឡែក។[6] ហើយ ស្ថានភាពអនីតិសង្វាសក៏អាចនៅមានអត្ថិភាពផងដែរ។

លើសពីនេះ ដោយសារតែការវិវត្តនៃរបបគតិយុត្តក្នុងសង្គម កម្ពុជាមានក្រមរដ្ឋប្បវេណីថ្មីមួយទៀតនៅឆ្នាំ ២០០៧ ដែលគ្រប់គ្រងលើទំនាក់ទនងញាតិ និងទំនាក់ទំនងទ្រព្យសម្បត្តិ។ ក្នុងនោះ បញ្ញត្តិស្ដីពីអាពាហ៍ពិពាហ៍ត្រូវបានតាក់តែងឡើង ដែលកំណត់ឱ្យមានអាពាហ៍ពិពាហ៍ស្របច្បាប់ ឬ សហ័ទ្ធ។ ដូចនេះ ស្ថិតក្រោមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ និងលិខិតបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធផ្សេងៗទៀត តើសហព័ទ្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនដូចម្ដេច? ជាមួយគ្នានេះ ការរស់នៅក្នុងស្ថានភាពអនីតិសង្វាសក៏នៅមានអត្ថិភាពផងដែរ ដូចនេះ ស្ថិតក្រោមការបកស្រាយក្នុងរបបគតិយុត្តថ្មីនេះ តើអនីតិសង្វាសជនគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនដោយរបៀបណាដែរ?

ដូចច្នេះ ខាងក្រោមនេះនឹងធ្វើការឆ្លើយនឹងសំណួរខាងលើដោយធ្វើការបកស្រាយទៅលើពីរចំណុច គឺ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ (**១.១**) និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិសង្វាសជន (**១.២**)។

## ១.១- ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ

ជាទូទៅ សហព័ទ្ធអាចសម្រេចចិត្តដោយសេរីអំពីទំនាក់ទំនងទ្រព្យសម្បត្តិរបស់ខ្លួន ដោយអាចជ្រើសរើសនូវប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធណាមួយដែលមានកំណត់នៅក្នុងបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី។ នៅពេល

[5] អេង សុត, ១៩៦៧, *ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុង ក្រមរដ្ឋប្បវេណី*, មាត្រា ២៥០-២៥៨។

[6] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ, លេខ ៥៦ ក្រ, ២០ កក្កដា ១៩៨៩, មាត្រា ៣២-៣៤។

រៀបអាពាហ៍ពិពាហ៍ សហព័ទ្ធអាចអនុវត្តតាមប្រព័ន្ធដែលធ្វើការសម្រេចអំពីទំនាក់ទំនងទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដែលហៅថា ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា (១.១.១) ឬ ក្នុងករណីដែលសហព័ទ្ធមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ នោះទំនាក់ទំនងអំពីទ្រព្យសម្បត្តិរបស់សហព័ទ្ធ នឹងត្រូវសម្រេចដោយវិធានច្បាប់ដែលហៅថា ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ (១.១.២)។

## ១.១.១- ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

នៅក្នុងទំនាក់ទំនងបុគ្គល និងបុគ្គល ដែលបានរៀបអាពាហ៍ពិពាហ៍ និងបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដែលមាននូវធនធានទ្រព្យសម្បត្តិជាចលនវត្ថុក្ដី ជាអចលនវត្ថុក្ដី គប្បីបញ្ជាក់ឱ្យបានច្បាស់អំពីសិទ្ធិទើលើទ្រព្យសម្បត្តិនោះ ថាតើធនធានទ្រព្យសម្បត្តិណាខ្លះជាសិទ្ធិរួម? ហើយធនធានទ្រព្យសម្បត្តិណាខ្លះ ជាសិទ្ធិផ្ដាច់មុខរបស់ភាគីណាមួយ? ករណីនេះ នៅប្រទេសជឿនលឿនមួយចំនួន ដើម្បីបើកឱកាសឱ្យភាគីអាចកំណត់ឱ្យបានច្បាស់លាស់នូវទំនាក់ទំនងទ្រព្យសម្បត្តិទាំងនោះ និងងាយស្រួលដល់ការដោះស្រាយវិវាទទៅលើទំនាក់ទំនងទ្រព្យសម្បត្តិ គេបានរៀបចំឱ្យមានបទប្បញ្ញត្តិ ដែលទាក់ទងទៅនឹង ការចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធ។ ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចធ្វើការចុះបញ្ជីកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយការរៀបអាពាហ៍ពិពាហ៍បាន[7] ដើម្បីកំណត់ឱ្យបានច្បាស់លាស់ អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្ដីប្រពន្ធ។ ដូចនេះ តើការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈកិច្ចសន្យាមានអត្ថប្រយោជន៍អ្វីខ្លះ (១.១.១.១)? ហើយ តើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធត្រូវបានបង្កើតឡើងដោយដូចម្ដេច (១.១.១.២)? ហើយ តើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធមានអានុភាពបែបណាខ្លះ (១.១.១.៣)?

### ១.១.១.១- អត្ថប្រយោជន៍នៃប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

ការបង្កើតឱ្យមានឡើងនូវប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺក្នុងគោលបំណងឱ្យការកំណត់នូវទ្រព្យសម្បត្តិរបស់សហព័ទ្ធទាំងសងខាងមានភាពពិតប្រាកដ ច្បាស់លាស់ មិនថាទ្រព្យនោះជាប្រភេទអចលទ្រព្យ ឬ ចលនទ្រព្យនោះទេ។ ក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ សហព័ទ្ធទាំងសងខាងអាចកំណត់ពីទំនាក់ទំនងសិទ្ធិ ករណីយកិច្ច និងទំនាក់ទំនងទ្រព្យសម្បត្តិ ដែលមានលក្ខណៈជាក់ស្ដែង ទៅតាមឆន្ទៈរបស់ពួកគេរៀងៗខ្លួន។ កិច្ចសន្យានេះអាចមានភាពបត់បែន ឬ ផ្លាស់ប្ដូរទៅតាមទំហំនៃទ្រព្យសម្បត្តិនិងប្រភពចំណូលរបស់ពួកគេ។ ហើយ វាក៏បានផ្ដល់នូវអត្ថប្រយោជន៍យ៉ាងច្រើនទៅដល់សហព័ទ្ធដូចខាងក្រោមនេះ។

#### ក- ការការពារអត្ថប្រយោជន៍សហព័ទ្ធទាំងសងខាង

ដោយយោងតាមទៅតាមក្រមរដ្ឋប្បវេណី បានអនុញ្ញាតឱ្យបុគ្គលដែលជាប្ដីប្រពន្ធធ្វើការចុះកិច្ចសន្យាទ្រព្យសម្បត្តិ មុន ឬ ក្រោយអាពាហ៍ពិពាហ៍បាន ដែលជាលក្ខណៈពិសេសក្នុងការធ្វើឱ្យមានភាពងាយស្រួលក្នុង

[7] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៦៦ កថាខណ្ឌទី១ វាក្យខណ្ឌទី១។

ការធ្វើឱ្យច្បាស់ការនូវទំនាក់ទំនងសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធ។ នៅក្នុងកិច្ចសន្យា ការកំណត់អំពីចំណែកទ្រព្យ ឬ ការទទួលទខុសត្រូវរបស់ភាគីនីមួយៗមានភាពប្រាកដប្រជា ដូច្នេះវាបានការពារផលប្រយោជន៍ភាគីម្ខាងចំពោះសិទ្ធិសេរីភាពលើការគ្រប់គ្រងទ្រព្យសម្បត្តិ និងការការពារពីការបំពានពីសហព័ទ្ធម្ខាងទៀត។

### ក.១- ការកំណត់លើសិទ្ធិ និងកាតព្វកិច្ចក្នុងកិច្ចសន្យា

ដោយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធអនុញ្ញាតដល់សហព័ទ្ធក្នុងការកំណត់នូវសិទ្ធិនិងកាតព្វកិច្ច នោះប្ដីប្រពន្ធទាំងសងខាងអាចកំណត់នូវ ៥ ដែលពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែកដូចជា៖

– **ទ្រព្យសម្បត្តិរួមត្រូវទទួលខុសត្រូវរួម៖** ចំពោះសោហ៊ុយអាពាហ៍ពិពាហ៍ប្ដីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត។[8] ប្ដីប្រពន្ធត្រូវមានករណីយកិច្ចក្នុងការចំណាយលើជីវភាពរួមនៃអាពាហ៍ពិពាហ៍ដោយតម្រូវឱ្យសហព័ទ្ធចែករំលែកសោហ៊ុយនេះទៅតាមទំហំនៃប្រាក់ចំណូល ឋានៈ ការងារ និងមុខរបររបស់ពួកគេ។ ការចំណាយលើសោហ៊ុយរួមសម្រាប់អាពាហ៍ពិពាហ៍ មិនមែនសំដៅតែលើចំណាយសំលៀកបំពាក់ ម្ហូបអាហារប្រចាំថ្ងៃ ការស្នាក់នៅនោះទេ តែសំដៅដល់ការចំណាយលើការសិក្សានិងថែទាំកូនផងដែរ។ ក្នុងករណីដែលសហព័ទ្ធណាដែលមិនបានបំពេញកាតព្វកិច្ចនៃសោហ៊ុយអាពាហ៍-ពិពាហ៍នោះទេ សហព័ទ្ធម្ខាងទៀតអាចធ្វើការស្នើសុំទៅតុលាការឱ្យចេញដីកាសម្រេចអំពីសោហ៊ុយអាពាហ៍ពិពាហ៍នោះបាន។ គួរបញ្ជាក់ផងដែរថា សិទ្ធិផ្ដាច់មុខ ដូចជាបំណុលគ្រួសារ គឺពួកគាត់មិនអាចចែងខសន្យាដើម្បីកាត់បន្ថយការទទួលខុសត្រូវបាននោះទេ។

– **ការទទួលខុសត្រូវដោយសាមគ្គី៖** ការទទួលខុសត្រូវដោយសាមគ្គី មានន័យថាជាការចូលរួមដោយសាមគ្គីភាពរបស់សហព័ទ្ធនៅក្នុងសោហ៊ុយអាពាហ៍ពិពាហ៍ រួមទាំងបំណុលផងដែរ។

– **ការតតាំងនឹងតតិយជន៖** ករណីសហព័ទ្ធណាម្នាក់ជាប់ទំនាក់ទំនងបំណុលជាមួយតតិយជន នោះសហព័ទ្ធដែលជាភាគីក្នុងកិច្ចសន្យានោះត្រូវតតាំងដោយផ្ទាល់ជាមួយម្ចាស់បំណុល។ ប្រសិនបើបំណុលដែលខ្ចីមកនោះកើតឡើងដោយសារតែការប្រើប្រាស់ ផ្គត់ផ្គង់ ឬ ក្នុងករណីចាំបាច់ណាមួយដើម្បីបម្រើដល់ប្រយោជន៍រួម នោះត្រូវមានការសាមគ្គីពីភាគីម្ខាងទៀតក្នុងការតតាំងចំពោះតតិយជន។ ប៉ុន្តែ ប្រសិនបើបំណុលដែលខ្ចីមកនោះកើតឡើងដោយសារតែប្រយោជន៍របស់សហព័ទ្ធម្ខាងដែលមិនមែនសម្រាប់បម្រើដល់ប្រយោជន៍រួម មិនគួរណាឱ្យមានការសាមគ្គីពីភាគីសហព័ទ្ធម្ខាងទៀតនោះទេ។

[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧១។

### ក.២- កំណត់សិទ្ធិគ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិក្នុងកិច្ចសន្យា

– **ការគ្រប់គ្រង៖** នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ សហព័ទ្ធអាចព្រមព្រៀងគ្នាថាទ្រព្យណាជាទ្រព្យរួម ទ្រព្យណាជាទ្រព្យដោយឡែកបានដោយឆន្ទៈភាគីទាំងសងខាង តែមិនអាចបំពានប្រយោជន៍ភាគីណាម្ខាងបានឡើយ។ ក្នុងការបង្កើតកិច្ចសន្យានេះ ការគ្រប់គ្រងនិងការចាត់ចែងទ្រព្យសម្បត្តិរួមក៏មិនអាចប្រាកចាកពីបញ្ញត្តិនៃទ្រព្យសម្បត្តិប្ដីប្រពន្ធតាមច្បាប់ដែរ។ ប្ដីប្រពន្ធមានសិទ្ធិស្មើៗគ្នាក្នុងការប្រើប្រាស់ គ្រប់គ្រងទ្រព្យសម្បត្តិដែលជាទ្រព្យរួមបាន ក៏ដូចជាទទួលផលប្រយោជន៍ដែលចេញពីទ្រព្យរួមនោះ។ ចំណែក ចំពោះទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធក៏មានសិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងទទួលផលប្រយោជន៍បានរៀងៗខ្លួន។ សហព័ទ្ធត្រូវប្រើប្រាស់ទ្រព្យសម្បត្តិរួមនៅក្នុងទំហំដែលចាំបាច់សម្រាប់ខ្លួនឯង និងសម្រាប់ជីវភាពគ្រួសារ។ ការគ្រប់គ្រងទ្រព្យសម្បត្តិត្រូវធ្វើឡើងដោយមានការសហការគ្នាល្អរវាងប្ដី និងប្រពន្ធ។ ក្នុងករណីណាមួយទាក់ទងនឹងភាពចាំបាច់សម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរួម សហព័ទ្ធម្ខាងអាចទាមទារឱ្យសហព័ទ្ធម្ខាងទៀតធ្វើចំណាត់ការបាន។ ប៉ុន្តែ បើការពិភាក្សាគ្នាលើការគ្រប់គ្រងទ្រព្យសម្បត្តិរួមមិនទទួលបានជោគជ័យ ឬ ភាគីមានភាពស្រពិចស្រពិល នោះពួកគេអាចទាមទារឱ្យតុលាការធ្វើការចាត់ចែងបាន។[9]

– **ការចាត់ចែង៖** នៅក្នុងការចាត់ចែងលើទ្រព្យសម្បត្តិ កិច្ចសន្យានេះអាចកំណត់នូវសិទ្ធិរបស់សហព័ទ្ធណាឱ្យធ្វើការចាត់ចែងលើទ្រព្យសម្បត្តិណាមួយបាន ដោយផ្អែកលើកម្មសិទ្ធិជាក់ស្ដែងរបស់សហព័ទ្ធណាមួយ។ សហព័ទ្ធអាចកំណត់ថាទ្រព្យដោយឡែកណាមួយអាចឱ្យមានការចាត់ចែងរួមដូចជាទ្រព្យរួមបាន។ ប៉ុន្តែ ទ្រព្យរួមមិនអាចធ្វើការចាត់ចែងដោយឡែកបានទេ លើកលែងករណីចាំបាច់សម្រាប់ផ្គត់ផ្គង់គ្រួសារ។ វាមានលក្ខណៈស្រដៀងគ្នានឹងបញ្ញត្តិនៃច្បាប់ដែរ ការចាត់ចែងទ្រព្យរួមត្រូវមានការយល់ព្រមពីសហព័ទ្ធទាំងសងខាង លើកលែងករណីចាំបាច់មួយចំនួនទាក់ទងនឹងការថែទាំជីវភាពគ្រួសារនោះគឺអាចអនុញ្ញាតឱ្យសហព័ទ្ធណាម្នាក់ធ្វើការលក់ ឬ ចាត់ចែងផ្សេងទៀតបានដោយមានការអនុញ្ញាតពីតុលាការ។

### ខ- ការរួមចំណែកក្នុងនីតិវិធីដោះស្រាយរបស់តុលាការ

នៅពេលសហព័ទ្ធដែលមិនបានប្រើប្រាស់ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធនេះទេ វាបានផ្ដល់ភាពលំបាកពេលដែលពួកគេដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការ ដោយតុលាការមានការលំបាកក្នុងការបើកស៊ើបអង្កេតលើទ្រព្យសម្បត្តិទាំងអស់ ហើយកំណត់ថាតើទ្រព្យណាមួយជាទ្រព្យដោយឡែក ទ្រព្យណាមួយជាទ្រព្យរួម។ ម៉្យាងទៀត

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧៤។

វាបានធ្វើឱ្យការងារនេះមានយឺតយ៉ាវដោយសារត្រូវការរយៈពេលយូរទៅតាមនីតិវិធី។ នៅពេលដែលសហព័ទ្ធបាន បង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះឡើង វាបានជួយសម្រួលដល់នីតិវិធីនានានៅពេលមានវិវាទដូចជាៈ

**ខ.១- វិវាទអំពីទ្រព្យពេលលែងលះ**

បើគ្មានកិច្ចសន្យាត្រូវឆ្លងកាត់នីតិវិធីតុលាការជាច្រើន នោះក្នុងពេលដែលសហព័ទ្ធធ្វើការលែងលះគ្នា អ្វីដែលមានភាពស្មុគស្មាញជាងគេគឺលើការបែងចែកទ្រព្យ។ ករណីដែលសហព័ទ្ធមិនបានធ្វើការចុះបញ្ជីទ្រព្យសម្បត្តិមុនមកទេ តុលាការត្រូវបើកនីតិវិធីស៊ើបអង្កេតលើទ្រព្យនិងបំណុលទាំងអស់ដែលសហព័ទ្ធមាន។ ជាក់ស្តែង តុលាការធ្វើការស្តាប់ ការអះអាងរបស់ភាគីទាំងសងខាងទៅលើទ្រព្យ ហើយធ្វើការសន្មតលើប្រភេទទ្រព្យតាមរយៈភស្តុតាងជាក់ស្តែង។ ករណីទ្រព្យដែលសហព័ទ្ធណាមួយមានមុនពេលរៀបអាពាហ៍ពិពាហ៍ សន្តតិកម្ម ជាអំណោយ ឬ ជាអច្ច័យទាន ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ត្រូវសន្មតជាទ្រព្យដោយឡែក។ ករណីទ្រព្យដែលសហព័ទ្ធទាំងពីរ ឬ សហព័ទ្ធម្ខាងរកបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យរួម។ ក្រោយមក តុលាការត្រូវធ្វើការបែងចែកទ្រព្យនោះ។ ប៉ុន្តែ ករណីដែលសហព័ទ្ធណាម្ខាង ជាប្រពន្ធក្តី ជាប្តីក្តី ត្រូវបានតុលាការកំណត់ឱ្យមានអំណាចមេបាទៅលើកូន (បើសិនមាន) នោះទ្រព្យរួមខ្លះត្រូវកាត់ទៅឱ្យភាគីជាអ្នកមានអំណាចមេបា។ ក្នុងការបែងចែកទ្រព្យនៅពេលមានការលែងលះ នោះតុលាការពិចារណាទៅលើភាពជាក់ស្តែងនៃទ្រព្យ និងភាពជិតស្និទ្ធរវាងភាគីជាម្ចាស់លើទ្រព្យនោះ។ ម៉្យាងទៀត ទ្រព្យខ្លះជាអចលនទ្រព្យ ឬ ទ្រព្យអវិភាគ ដែលមិនអាចបែងចែកជាចំណែកបាន ឬ មានការលំបាកក្នុងការបែងចែកដែលនាំឱ្យទ្រព្យនោះខូចតម្លៃ ដូចនេះតុលាការអាចឱ្យភាគីដែលទទួលបានទ្រព្យនោះកាត់សងជាប្រាក់ជំនួសទៅឱ្យភាគីម្ខាងទៀតទៅតាមតម្លៃទីផ្សារបាន។

**ខ.២- វិវាទអំពីទ្រព្យពេលបែងចែកមរតក**

នៅពេលបែងចែកមរតក តុលាការយកកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមកធ្វើជាមូលដ្ឋានក្នុងការបែងចែកថាតើទ្រព្យណាខ្លះជាចំណែកទ្រព្យរួមរបស់មត៌កជនដែលត្រូវបញ្ចូលក្នុងមរតក។ បើគ្មានកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទេ ជាដំបូងគេត្រូវកំណត់ជាមុន ថាតើទ្រព្យណាខ្លះជាទ្រព្យដោយឡែករបស់មត៌កជនសិន ទើបអាចយកទ្រព្យដោយឡែកនោះមកធ្វើជាមូលដ្ឋានក្នុងការបែងចែកមរតក។

គួរបញ្ជាក់ផងដែរថា ក្រមរដ្ឋប្បវេណីបានចែងពីគោលការណ៍ជ្រៀតជ្រែករបស់សហព័ទ្ធនៅរស់ក្នុងការចូលទៅចែកចំណែកមរតក ដោយសហព័ទ្ធនៅរស់នោះត្រូវជាសន្តតិជនជានិច្ច។ ក្នុងករណីដែលមានសន្តតិជនផ្សេងទៀត នោះលំដាប់របស់សហព័ទ្ធនៅរស់ គឺស្មើគ្នានឹងសន្តតិជនផ្សេងទៀតដែរ។[10]

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ១១៦១។

**ខ.៣- វិវាទអំពីទ្រព្យក្នុងករណីទាមទារឱ្យអនុវត្តភាគពូកិច្ច**

នៅពេលមានបណ្តឹងទាមទារឱ្យអនុវត្តនូវភាគពូកិច្ចភាគច្រើនមានការលំបាក ព្រោះប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាទ្រព្យ ដោយពេលខ្លះកម្មវត្ថុនោះអាចជាទ្រព្យរួមដែលមានចំណែកសហព័ទ្ធម្ខាងទៀត។ ដូច្នេះ តុលាការត្រូវចំណាយពេលវេលាធ្វើការស៊ើបអង្កេតអង្គហេតុជាថ្មីទៅលើទ្រព្យនោះ។ ក្នុងករណីកម្មវត្ថុនៃការទាមទារជាប់ពាក់ព័ន្ធលើចំណែកទ្រព្យរួមដែលសហព័ទ្ធម្ខាងទៀតក៏ជាកម្មសិទ្ធិករ នោះតុលាការត្រូវធ្វើការបែងចែកចំណែកនៃទ្រព្យនោះត្រឹមទំហំពាក់កណ្តាល ឬ តាមកម្រិតដែលមានចែងក្នុងកិច្ចសន្យាដែលសហព័ទ្ធមានសិទ្ធិលើ។ ករណីខ្លះទ្រព្យនោះជាទ្រព្យអវិភាគដែលពិបាកក្នុងការបែងចែកចំណែកដែលអាចធ្វើឱ្យខូចតម្លៃ នោះតុលាការអាចចេញសាលក្រមអនុវត្តលក់ទ្រព្យតាមតម្លៃទីផ្សារ ហើយសងម្ចាស់បំណុលបាន។

**១.១.១.២- អំពីការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

**ក- លក្ខខណ្ឌគ្រឹះ**

ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មិនខុសពីទម្រង់កិច្ចសន្យាផ្សេងៗទៀតទេ គឺបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឬ សហព័ទ្ធត្រូវបំពេញលក្ខខណ្ឌគ្រឹះសំខាន់ៗដូចជាការព្រមព្រៀងរវាងភាគី សមត្ថភាពចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

**ក.១- ការព្រមព្រៀងរវាងភាគី**

ការព្រមព្រៀងគឺជាការបង្ហាញឆន្ទៈរបស់ភាគី ដែលមានបំណងបង្កើតអានុភាពគតិយុត្ត មានន័យថាអនាគតប្តីប្រពន្ធ ឬ សហព័ទ្ធត្រូវមានការព្រមព្រៀង ឬ ឆន្ទៈក្នុងការបង្កើតកិច្ចសន្យាជាមួយគ្នា។ កិច្ចសន្យានេះគឺត្រូវតែយល់ព្រមទាំងពីរនាក់ ប្រសិនបើមានអនាគតប្តីប្រពន្ធ ឬ សហព័ទ្ធតែម្ខាងចង់បង្កើតកិច្ចសន្យានេះជាឯកតោភាគី ឬ មានឆន្ទៈតែម្ខាង កិច្ចសន្យានេះគឺមិនអាចបង្កើតឱ្យមានអានុភាពឡើយ។

**ក.២- សមត្ថភាពចុះកិច្ចសន្យា**

សមត្ថភាពចុះបញ្ជីកិច្ចសន្យា សំដៅលើសមត្ថភាពក្នុងការបង្ហាញឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព។ បុគ្គលដែលមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ត្រូវតែជានីតិជនដែលមានអាយុ ១៨ ឆ្នាំឡើងទៅ និងអនីតិជនដែលទទួលបាននូវអត្តាធីនភាព ដែលមានសិទ្ធិក្នុងការធ្វើកិច្ចសន្យាដោយឯករាជខ្លួនឯងបាន លើកលែងតែជនទាំងពីរប្រភេទនេះត្រូវបានកម្រិតសមត្ថភាពប៉ុណ្ណោះ។

**ក.៣- កម្មវត្ថុនៃកិច្ចសន្យា**

កម្មវត្ថុ សំដៅការកំណត់សិទ្ធិ និងករណីយកិច្ចទៅលើទ្រព្យសម្បត្តិ ដោយសហព័ទ្ធអាចកំណត់ពីការគ្រប់គ្រងទ្រព្យសម្បត្តិរួម ឬ ទ្រព្យសម្បត្តិដោយឡែក ឬ កម្មវត្ថុណាផ្សេងតាមរយៈនៃការព្រមព្រៀងនេះ។

បុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឬ សហព័ទ្ធអាចកំណត់កម្មវត្ថុនៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធបានដូចជា៖

- ទ្រព្យសម្បត្តិដោយឡែកដាក់ឱ្យទៅជាទ្រព្យសម្បត្តិរួម។
- ទ្រព្យសម្បត្តិរួមដាក់ឱ្យទៅជាទ្រព្យសម្បត្តិដោយឡែក។
- កំណត់អំពីទំនាក់ទំនងកាតព្វកិច្ច និងសិទ្ធិលើបំណុលពិសេស ការចាត់ចែងកាតព្វកិច្ចដែលមានមុនរៀបអាពាហ៍ពិពាហ៍ និងបន្ទុកនៃកាតព្វកិច្ចដែលអាចនឹងកើតឡើងក្រោយអាពាហ៍ពិពាហ៍ និងកំណត់អំពីសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ប្ដី ឬ ប្រពន្ធ។

យ៉ាងណាមិញ កម្មវត្ថុនៃកិច្ចសន្យានេះមិនត្រូវបំពានសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុង និងមិនត្រូវផ្ទុយទៅនឹងសណ្ដាប់ធ្នាប់សាធារណៈឡើយ។[11]

**ខ- លក្ខខណ្ឌទម្រង់**

កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ ក្នុងករណីដែលប្ដីប្រពន្ធបានធ្វើកិច្ចសន្យាផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេ មិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ។[12]

ដូចនេះ ដើម្បីអាចទទួលបាននូវលក្ខខណ្ឌតតាំង បុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឬ សហព័ទ្ធអាចទៅចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធបាននៅក្រសួងយុត្តិធម៌ ហើយបែបបទ និងទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធត្រូវអនុលោមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ពោលគឺប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។[13]

**ខ.១- ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

រាល់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ពាក្យសុំច្បាប់ដើម ត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ដោយភ្ជាប់មកជាមួយនូវច្បាប់ថតចម្លងនៃច្បាប់ដើមនោះ។ បុគ្គល ឬ អ្នកតំណាង (ប្រសិនបើមាន) ដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវយកពាក្យសុំនោះមកដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌។ ជាគោលការណ៍ ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវធ្វើឡើងរួមគ្នា លើកលែងតែករណីដូចខាងក្រោម ដែលអាចដាក់ពាក្យសុំតែម្នាក់ឯងបាន៖

[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៦៩ កថាខណ្ឌទី១។

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧០។

[13] ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/00៧, ៣១ ឧសភា ២០១១, មាត្រា ២៦ និងមាត្រា ២៧។

ក- ការផ្លាស់ប្តូរ ឬ ការកែតម្រូវតែ ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។

ខ- ការចុះបញ្ជី ដោយផ្អែកលើសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចស្ថាពរ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដូចមានចែងនៅក្នុងមាត្រា ៣០ កថាខណ្ឌទី៣ ចំណុច ខ, គ , ឃ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។[14]

– ប្រសិនបើមានសេចក្តីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិ ក្នុងសាលក្រម ឬ សាលដីការំលាយអាពាហ៍ពិពាហ៍ដែលបានចូលជាស្ថាពរ គឺអតីតសហព័ទ្ធណាម្នាក់ (ចំណុច ខ)
– ប្រសិនបើតុលាការបានសម្រេចសេចក្តីអំពីការបែងចែកទ្រព្យសម្បត្តិ ដោយការរំលាយអាពាហ៍-ពិពាហ៍ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយសេចក្តីសម្រេចនោះចូលជាស្ថាពរ គឺអតីតសហព័ទ្ធណាម្នាក់ (ចំណុច គ)
– ប្រសិនបើហេតុការណ៍ដែលរំលាយកំជាប់ពាក្យ ត្រូវបានបញ្ជាក់ដោយជាក់លាក់ នៅក្នុងសាលក្រម ឬ សាលដីកាស្ថាពរ ដែលសម្រេចអំពីការទាមទារដោយផ្អែកលើហេតុការណ៍រំលាយកំជាប់ពាក្យ គឺភាគីណាម្នាក់ (ចំណុច ឃ)។

ទន្ទឹមនឹងនេះ ដើម្បីអាចឱ្យការចុះបញ្ជីប្រព្រឹត្តទៅបានតាមច្បាប់ បុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឬ សហព័ទ្ធ ត្រូវបំពេញពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធតាមទម្រង់ដែលបានកំណត់ ព្រមទាំងត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនផងដែរ។[15]

- **ទម្រង់នៃពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ៖** ទម្រង់នៃពាក្យសុំចុះបញ្ជី ត្រូវសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ពាក្យសុំចុះបញ្ជី ឈ្មោះនិងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន) ហើយត្រូវគោរពចូលមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងមានចុះកាលបរិច្ឆេទ និងហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ។[16] ក្រៅពីចំណុចខាងលើ ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម៖

ក- ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)

[14] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ៩ សីហា ២០១៣, ប្រការ ១៥។

[15] ទម្រង់នៃពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ព្រមទាំងឯកសារភ្ជាប់ មានកំណត់ក្នុងឧបសម្ព័ន្ធទី១។

[16] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ៩ សីហា ២០១៣, ប្រការ ១៦ កថាខណ្ឌទី១។

ឃ- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ង- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍។[17]

- **ឯកសារភ្ជាប់នៃពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ៖**
  - កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
  - សំបុត្រអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍
  - វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុភោគ) ក្នុងករណីដែលកិច្ចសន្យានេះពាក់ព័ន្ធនឹងបញ្ហាដីធ្លី
  - លិខិតប្រគល់សិទ្ធិអ្នកតំណាង (ប្រសិនបើមាន)
  - អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន។[18]

### ខ.២- នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

កិច្ចការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។ បញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធត្រូវរក្សាទុកនៅក្រសួងយុត្តិធម៌។ ដើម្បីធ្វើការចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធឱ្យទទួលបានជោគជ័យ សហព័ទ្ធ ឬ បុគ្គលដែលនឹងរៀបអាពាហ៍ពិបាហ៍ជាមួយគ្នា ចាំបាច់ត្រូវតែបន្តនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធ បន្ទាប់ពីបំពេញលក្ខខណ្ឌទាំងអស់រួចរាល់ហើយ។ នីតិវិធីទាំងនោះរួមមាន៖

- **ការទទួលពាក្យសុំចុះបញ្ជី៖** នៅពេលមន្ត្រីចុះបញ្ជីបានទទួលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចុះនិទ្ទេសនៅលើពាក្យសុំនោះនូវលេខរៀងទទួលពាក្យសុំ កាលបរិច្ឆេទ និងឈ្មោះនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ព្រមទាំងហត្ថលេខាបំពេញ និងឈ្មោះមន្ត្រីចុះបញ្ជីនោះ។ យ៉ាងណាមិញ ពាក្យសុំចុះបញ្ជីអាចដកបានមុនពេលការចុះបញ្ជីត្រូវបានបញ្ចប់ ដោយត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។[19]
- **ការពិនិត្យពាក្យសុំចុះបញ្ជី៖** មន្ត្រីចុះបញ្ជីត្រូវពិនិត្យពាក្យសុំ និងឯកសារភ្ជាប់។ នៅពេលពិនិត្យពាក្យសុំ បើមន្ត្រីចុះបញ្ជីមានវិមតិសង្ស័យ នោះមន្ត្រីចុះបញ្ជីអាចធ្វើការសាកសួរបន្ថែមទៅអ្នកដាក់ពាក្យសុំ ឬ អ្នកតំណាងនោះបាន។ ក្នុងករណីដែលមន្ត្រីចុះបញ្ជីពិនិត្យឃើញថាពាក្យសុំចុះបញ្ជីធ្វើឡើងពុំត្រឹមត្រូវ

---

[17] ប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ៩ សីហា ២០១៣, ប្រការ ១៩ កថាខណ្ឌទី២ វាក្យខណ្ឌទី១។

[18] ប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ៩ សីហា ២០១៣, ប្រការ ១៩ កថាខណ្ឌទី២ វាក្យខណ្ឌទី២។

[19] ប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ៩ សីហា ២០១៣, ប្រការ ២៩ និងប្រការ ៣០។

មន្ត្រីចុះបញ្ជីត្រូវចេញលិខិតបង្គាប់ឱ្យកែតម្រូវដោយកំណត់អំឡុងពេលសមរម្យ និងជូនដំណឹងទៅអ្នកដាក់ពាក្យសុំ។ ពាក្យសុំចុះបញ្ជីអាចធ្វើឡើងដោយពុំត្រឹមត្រូវក្រោមមូលហេតុមួយចំនួន៖

- ព័ត៌មាន និងបែបបទក្នុងពាក្យសុំចុះបញ្ជីមិនស្របតាមប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ពុំបានផ្តល់ឯកសារដែលចាំបាច់
- ខ្លឹមសារនៅក្នុងពាក្យសុំ និងឯកសារភ្ជាប់មិនស្របគ្នា
- ពាក្យសុំចុះបញ្ជីនោះធ្លាប់បានដាក់ និងចុះបញ្ជីម្តងរួចមកហើយ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំនៅក្នុងពាក្យសុំ មិនស្របគ្នាជាមួយនឹងការចុះបញ្ជី
- ពុំបានបង់សោហ៊ុយ ឬ
- ពាក្យសុំនោះ មិនអនុលោមតាមលក្ខខណ្ឌនៃប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ ច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធ។

ក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជី ពុំបានកែតម្រូវនៅក្នុងអំឡុងពេលសមរម្យនោះទេ មន្ត្រីចុះបញ្ជីត្រូវចេញលិខិតលើកចោលពាក្យសុំចុះបញ្ជីនោះ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំ។ ក្នុងករណីនេះ មន្ត្រីចុះបញ្ជីត្រូវប្រគល់ឯកសារភ្ជាប់ឱ្យទៅអ្នកដាក់ពាក្យសុំវិញ បើមានការស្នើសុំ។[20]

- **ពាក្យសុំឱ្យពិនិត្យឡើងវិញចំពោះការលើកចោលរបស់មន្ត្រីចុះបញ្ជី៖** ក្នុងករណីមានការលើកចោលពាក្យសុំរបស់មន្ត្រីចុះបញ្ជី អ្នកដាក់ពាក្យសុំចុះបញ្ជីមានសិទ្ធិដាក់ពាក្យសុំឱ្យពិនិត្យឡើងវិញទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និង សម្រេច ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំនោះ។[21]

បន្ទាប់ពីមន្ត្រីចុះបញ្ជីបានពិនិត្យពាក្យសុំ និងឯកសារភ្ជាប់រួច មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកចុះបញ្ជីនូវចំណុចដូចខាងក្រោម៖

- ឈ្មោះ អាសយដ្ឋាន និងថ្ងៃ ខែ ឆ្នាំកំណើតរបស់ភាគីនៃកិច្ចសន្យា
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបចំអាពាហ៍ពិពាហ៍ជាមួយគ្នា
- កាលបរិច្ឆេទនៃថ្ងៃរៀបចំអាពាហ៍ពិពាហ៍
- គោលបំណងនៃការចុះបញ្ជី

[20] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ៩ សីហា ២០១៣, ប្រការ ៣១ ប្រការ ៣២ និងប្រការ ៣៣។

[21] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ៩ សីហា ២០១៣, ប្រការ ៣៤។

– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)។ ចំពោះសន្លឹកចុះបញ្ជីនេះ មន្ត្រីចុះបញ្ជីត្រូវចុះលេខបញ្ជីផ្អែកលើលេខរៀងទទួលពាក្យសុំ ហើយចុះហត្ថលេខាបំពេញដើម្បីបញ្ជាក់ថា "**បានពិនិត្យរួច**" រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។ បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រូណូ ទៅតាមលំដាប់លេខចុះបញ្ជី។[22]

### ខ.៣- អានុភាពនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ

ជាទូទៅ អានុភាពនៃការចុះបញ្ជីនេះ គឺការចុះបញ្ជីនៃកិច្ចសន្យាទ្រព្យសម្បត្តិដែលត្រូវធ្វើឡើងតាមនីតិវិធីដែលមានចែងនៅក្នុងប្រកាសស្តីពីនីតិវិធីនៃការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទៅតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ដូចដែលរៀបរាប់ពីខាងលើ។ លើសពីនេះ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មានអានុភាពនៅពេលចុះហត្ថលេខា និងប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[23]

### ១.១.១.៣- អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាកិច្ចសន្យាមួយប្រភេទដែលមានភាពងាយស្រួល និងច្បាស់លាស់ក្នុងការកំណត់លើបញ្ហាសំខាន់ៗនៃទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលមានដូចជាសិទ្ធិ កាតព្វកិច្ច ការគ្រប់គ្រង ការចាត់ចែង និងករណីយកិច្ចនានា ដែលទាមទារឱ្យប្តីប្រពន្ធត្រូវគោរព និងអនុវត្តតាម។ ដើម្បីឱ្យកិច្ចសន្យាមួយនេះមានអានុភាពគតិយុត្ត ភាគីជាប្តីប្រពន្ធត្រូវគោរពតាមការកំណត់នៃច្បាប់ដើម្បីជៀសវាងបញ្ហានៅថ្ងៃមុខ។

#### ក- អានុភាពចំពោះភាគី

នៅពេលប្តីប្រពន្ធបានសម្រេចចិត្តចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធនេះទៅតាមគោលការណ៍ច្បាប់ ដែលបានកំណត់ដោយគោរពនូវឆន្ទៈរបស់ភាគីទាំងសងខាង នោះអានុភាពត្រូវមានចំពោះទ្រព្យសម្បត្តិភាគីទាំងសងខាង។ ករណីនេះ អានុភាពនៃកិច្ចសន្យាមានទៅលើទំហំទ្រព្យសម្បត្តិដែលសហព័ទ្ធបានចុះបញ្ជីនៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិ។ ទាំងទ្រព្យសម្បត្តិរួម ទាំងទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធដែលបានកំណត់ក្នុងកិច្ចសន្យានេះបានកំណត់ពីសិទ្ធិ និងកាតព្វកិច្ចរួចហើយ។ ដូចនេះ អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិចំពោះភាគីនេះ ចង់សំដៅទៅលើទំហំនៃសិទ្ធិទាក់ទងនឹងការលក់ ឬ ចាត់ចែងអ្វីមួយត្រូវគោរពលើឆន្ទៈភាគីដែលជាម្ចាស់កម្មសិទ្ធិ។ ប៉ុន្តែ ករណីខ្លះ ដោយសារតែមានភាគីម្ខាងជំពាក់ពំណុលគេ ហើយគ្មានលទ្ធភាពសង នោះម្ចាស់បំណុលអាចរឹបអូសត្រឹមទ្រព្យសម្បត្តិដែលកូនបំណុលមាន តែមិនអាចរឹបអូសនូវទ្រព្យរួមទេ ពោលគឺអាចរឹបអូសត្រឹមតែចំណែកទ្រព្យដោយឡែករបស់ភាគីប្តី ឬ ប្រពន្ធជាកូនបំណុលប៉ុណ្ណោះ។

[22] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ៩ សីហា ២០១៣, ប្រការ ៣៨។

[23] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ៩ សីហា ២០១៣, ប្រការ ៣៦។

**ខ-អានុភាពចំពោះតតិយជន**

ក្រៅពីមានអានុភាពចំពោះភាគី កិច្ចសន្យានេះក៏មានអានុភាពចំពោះតតិយជនផងដែរ។ អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិចំពោះតតិយជន គឺចង់សំដៅទៅលើតតិយជនមិនថាជារូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានប្រយោជន៍នៅក្នុងរង្វង់ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធនោះ។ ក្នុងករណីតតិយជនដែលមានប្រយោជន៍ក្នុងរង្វង់ទ្រព្យសម្បត្តិនៃប្តីប្រពន្ធណាមួយ ឬ ចង់ដឹងពីការកំណត់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្នុងគោលដៅរកភាពច្បាស់លាស់មុនសម្រេចចិត្តរកស៊ី ឬ ធ្វើទំនាក់ទំនងកិច្ចសន្យាផ្សេងៗ តតិយជននោះអាចស្នើសុំឱ្យចេញលិខិតបញ្ជាក់នៃកិច្ចសន្យាទ្រព្យសម្បត្តិនេះបាន។

## ១.១.២- ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

ក្នុងករណីដែលសហព័ទ្ធមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នោះទំនាក់ទំនងអំពីទ្រព្យសម្បត្តិរបស់សហព័ទ្ធ នឹងត្រូវសម្រេចដោយវិធានច្បាប់ដែលហៅថា ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។ ក្នុងនោះ សហព័ទ្ធមានទ្រព្យសម្បត្តិពីរប្រភេទ គឺទ្រព្យសម្បត្តិសកម្ម និង ទ្រព្យសម្បត្តិអកម្ម។ ដូចនេះ ខាងក្រោមនេះនឹងផ្តល់នូវបញ្ញត្តិដល់សហព័ទ្ធដើម្បីដោះស្រាយបញ្ហាក្នុងការគ្រង់គ្រង ទ្រព្យសកម្ម (**១.១.២.១**) និង ទ្រព្យសម្បត្តិអកម្ម (**១.១.២.២**)។

### ១.១.២.១- ទ្រព្យសម្បត្តិសកម្មរបស់សហព័ទ្ធ

ទ្រព្យសម្បត្តិសកម្មរបស់សហព័ទ្ធមានពីរប្រភេទ គឺទ្រព្យសម្បត្តិដោយឡែក និង ទ្រព្យសម្បត្តិរួម។

**ក- ទ្រព្យសម្បត្តិដោយឡែក**

**ក.១- សញ្ញាណនៃទ្រព្យសម្បត្តិដោយឡែក**

នៅក្នុងក្រមរដ្ឋប្បវេណី មាត្រា ៩៧២ បានកំណត់ពីអត្ថិភាពនៃទ្រព្យសម្បត្តិដោយឡែក ហើយទ្រព្យសម្បត្តិនេះត្រូវស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់។ ទ្រព្យសម្បត្តិដែលត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធណាម្នាក់ អាចស្ថិតក្នុងករណីណាមួយដូចខាងក្រោម៖

- ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។ **<u>ឧទាហរណ៍</u> ក** បានទិញរថយន្តមួយគ្រឿងមុនចុះសំបុត្រអាពាហ៍ពិបាហ៍ជាមួយ ខ។ ដូចនេះ រថយន្តមួយគ្រឿងនេះ គឺជាទ្រព្យសម្បត្តិដោយឡែករបស់ **ក**។
- ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។
  – **ប្រទានកម្ម៖** **<u>ឧទាហរណ៍</u>** ក្រោយពីរៀបអាពាហ៍ពិពាហ៍ជាមួយនឹង **ខ** ម្តាយមីងរបស់ **ក** បានប្រគល់ផ្ទះមួយល្វែងឱ្យ ក ។ ក្នុងករណីនេះ ទោះជាប្រទានកម្មបានធ្វើឡើងក្នុងអំឡុងពេលដែល **ក**

មានចំណងអាពាហ៍ពិពាហ៍ជាមួយ **ខ** ក៏ដោយ ក៏ផ្ទះល្វែងនេះត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិដោយឡែករបស់ **ក** ដែរ។

- **សន្តតិកម្ម៖** <u>**ឧទាហរណ៍**</u> ក្រោយពីរៀបអាពាហ៍ពិពាហ៍ជាមួយនឹង **ខ** ឪពុករបស់ **ក** បានទទួលមរណភាព។ ក្នុងករណីនេះ គឺមានតែ **ក** តែប៉ុណ្ណោះដែលជាសន្តតិជន ចំណែកឯ **ខ** មិនមែនជាសន្តតិជនទេ។ ដូចនេះ ទ្រព្យរបស់ **ក** ដែលបានតាមរយៈសន្តតិកម្មខាងលើ ត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិដោយឡែក។
- **អច្ច័យទាន៖** <u>**ឧទាហរណ៍**</u> ក្រោយពីរៀបអាពាហ៍ពិពាហ៍ជាមួយនឹង **ខ** ឪពុកមារបស់ **ក** បានបាត់បង់ជីវិត ដោយបន្សល់ទុកនូវបណ្តាំដែលមានខ្លឹមសារថា ប្រគល់រថយន្តមួយគ្រឿងឱ្យទៅ **ក**។ ដូចនេះ រថយន្តមួយគ្រឿងនេះ គឺជាទ្រព្យសម្បត្តិដោយឡែករបស់ **ក** ទោះបានទទួលក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ជាមួយ **ខ** ក៏ដោយ។

- ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែកស្ថិតក្នុងករណីទាំងពីរខាងលើ។ <u>**ឧទាហរណ៍**</u> មុនរៀបអាពាហ៍ពិពាហ៍ជាមួយ **ក** មានផ្ទះមួយល្វែង។ ជាគោលការណ៍ ផ្ទះនេះគឺជាទ្រព្យសម្បត្តិដោយឡែករបស់ **ក**។ ប៉ុន្តែ ក្រោយពីរៀបអាពាហ៍ពិពាហ៍ជាមួយនឹង **ខ ក** ក៏បានលក់ផ្ទះនោះក្នុងតម្លៃ ៥០០០ ដុល្លារ។ ទោះប្រាក់នេះបានកើតឡើងក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ជាមួយ **ខ** ក៏ដោយ ដោយសារប្រាក់នេះគឺជាតម្លៃតបនៃទ្រព្យសម្បត្តិដោយឡែករបស់ **ក** ដូចនេះប្រាក់នេះក៏ត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិដោយឡែករបស់ **ក** ផងដែរ។

### ក.២- ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដោយឡែក

ចំពោះទ្រព្យសម្បត្តិដោយឡែក ជាគោលការណ៍ សហព័ទ្ធដែលជាម្ចាស់ទ្រព្យមានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន។[24] ប៉ុន្តែ ក្នុងករណីខ្លះ ច្បាប់បានទទួលស្គាល់នូវសិទ្ធិអាស្រ័យនៅលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាង ដោយសហព័ទ្ធម្ខាងទៀតក្នុងករណីដែលទ្រព្យសម្បត្តិដោយឡែកនោះត្រូវបានប្រើប្រាស់ជាអចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់ប្តីប្រពន្ធ។ លើសពីនេះទៅទៀតនោះ សិទ្ធិនេះអាចអះអាងបានចំពោះគ្រប់បុគ្គលទាំងអស់ ទោះបីជាសហព័ទ្ធម្ខាងដែលជាម្ចាស់បានចាត់ចែងអចលនវត្ថុនោះក៏ដោយ ក៏សហព័ទ្ធម្ខាងទៀតអាចបន្តអាស្រ័យនៅអចលនវត្ថុនោះបានដែរ។[25]

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧៧។

យ៉ាងណាមិញ សិទ្ធិអាស្រ័យនៅលើអចលនវត្ថុដែលជាទ្រព្យដោយឡែករបស់សហព័ទ្ធម្ខាងពីសំណាក់សហព័ទ្ធម្ខាងទៀតនេះ ត្រូវបានចាត់ទុកថារលត់ នៅពេលភាគីទាំងពីរលែងជាសហព័ទ្ធនឹងគ្នាតទៅទៀត។[26]

### ខ- ទ្រព្យសម្បត្តិរួម

#### ខ.១- សញ្ញាណនៃទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយណា ដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដោយឡែកដែលទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ព្រមទាំងតម្លៃតបរបស់ទ្រព្យសម្បត្តិនោះ។[27] ដូច្នេះ ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធអាចជា៖

- ចំណូលបានពីការងាររបស់សហព័ទ្ធម្នាក់ៗ រួមមាន ប្រាក់បៀវត្ស។ ល។
- ផលចំណេញ ឬ ផលប្រយោជន៍ (អត្ថប្រយោជន៍ដែលកើតពីវត្ថុអ្វីមួយ ដូចជា ប្រាក់ថ្លៃឈ្នួលអាគារ ឬ ប្រាក់ចំណេញពីអាជីវកម្មភោជនីយដ្ឋាន) នៃទ្រព្យសម្បត្តិដោយឡែក។[28]

#### ខ.២- ការគ្រប់គ្រង និង ការប្រើប្រាស់ទ្រព្យសម្បត្តិរួម[29]

ចំពោះទ្រព្យសម្បត្តិរួម សហព័ទ្ធនីមួយៗមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រង ទ្រព្យសម្បត្តិរួមនោះ។ ក្នុងនោះ សហព័ទ្ធ មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួមនៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព ពោលគឺចាំបាច់សម្រាប់ផ្គត់ផ្គង់គ្រួសារ។ បន្ថែមពីនេះ សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយអនុម័តយកគោលការណ៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នា ដោយភាគីម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀត ឱ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និង រក្សាទុកនូវទ្រព្យសម្បត្តិរួមនោះ។ ក្នុងករណី ប្តីប្រពន្ធពិភាក្សាអំពីការគ្រប់គ្រង ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនបានសម្រេច ឬ ពុំអាចពិភាក្សាគ្នាបានទេ ភាគីប្តី ឬ ប្រពន្ធអាចទាមទារទៅតុលាការឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន ដើម្បីដោះស្រាយវិវាទលើការគ្រប់គ្រងទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ។

---

[26] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ២០១៧, *សៀវភៅជំនួយស្មារតី នីតិវិធីព្រហ្មទណ្ឌ និង នីតិគ្រួសារ*, ទំព័រ៣៦៥។

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧៣។

[28] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ២០១៧, *សៀវភៅជំនួយស្មារតី នីតិវិធីព្រហ្មទណ្ឌ និង នីតិគ្រួសារ*, ទំព័រ៣៥៩។

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧៤។

### ខ.៣- ការចាត់ចែងទ្រព្យសម្បត្តិរួម[30]

ជាគោលការណ៍ បើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនអាចយកទៅលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតបានឡើយ មានន័យថា ដើម្បីអាចយកទ្រព្យសម្បត្តិរួមប្តីប្រពន្ធទៅលក់ ឬ ចាត់ចែងផ្សេងទៀតបាន ដាច់ខាតត្រូវតែមានការយល់ព្រមពីប្តីប្រពន្ធជាមុនសិន។ ប៉ុន្តែ បើមានស្ថានភាពមិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និង ដើម្បីរក្សាជីវភាពរស់នៅ នោះប្តីប្រពន្ធណាម្ខាង អាចលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀត នូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ។ លើសពីនេះទៅទៀតនោះ ក្នុងករណីដែលប្តី ឬ ប្រពន្ធណាម្ខាងបានធ្វើការខាត់ចែងទ្រព្យសម្បត្តិរួម ដោយពុំមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ឬ ក៏ពុំមានការអនុញ្ញាតពីតុលាការទេ ភាគីម្ខាងទៀតអាចទាមទារឱ្យតុលាការសម្រេចលុបចោលការចាត់ចែងនោះបាន៖

- បើជាអចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ (លំនៅឋានគ្រួសារ)៖ ត្រូវប្តឹងក្នុងអំឡុងពេល ២ ឆ្នាំ ដោយគិតចាប់ពីដែលបានដឹងពីការចាត់ចែងនោះ។
- បើជាទ្រព្យសម្បត្តិផ្សេងទៀត (ក្រៅពីលំនៅដ្ឋានគ្រួសារ)៖ ត្រូវប្តឹងក្នុងអំឡុងពេល ១ ឆ្នាំ ដោយគិតចាប់ពីដែលបានដឹងពីការចាត់ចែងនោះ។

## ១.១.២.២- ទ្រព្យសម្បត្តិអកម្មរបស់សហព័ទ្ធ

ក្រៅពីទ្រព្យសម្បត្តិសកម្ម សហព័ទ្ធក៏អាចមានទ្រព្យសម្បត្តិអកម្មដែលជាកាតព្វកិច្ច ឬ បំណុលផងដែរ ដោយកាតព្វកិច្ច ឬ បំណុលខ្លះបានកើតឡើងនៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ឬ មុនពេលមានចំណងអាពាហ៍ពិពាហ៍។[31]

### ក- កាតព្វកិច្ចដែលកើតឡើងក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍

ជាធម្មតា កាតព្វកិច្ច ឬ បំណុលដែលកើតឡើងនៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍អាចជា៖

- **កាតព្វកិច្ចដែលសហព័ទ្ធត្រូវទទួលខុសត្រូវដោយសាមគ្គី**[32] គឺជាបន្ទុកនៃកាតព្វកិច្ចរបស់ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ ដែលរួមមានដូចជា៖

---

[30] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧៦។

[31] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ២០១៧, *សៀវភៅជំនួយស្មារតី នីតិវិធីព្រហ្មទណ្ឌ និង នីតិគ្រួសារ*, ទំព័រ៣៦៥-៣៧៤។

[32] កាតព្វកិច្ចដោយសាមគ្គី (មាត្រា ៩២១ កថាខណ្ឌទី ១)៖ ក្នុងករណីដែលបុគ្គលច្រើននាក់ទទួលបន្ទុកនូវកាតព្វកិច្ចសាមគ្គី ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលណាម្នាក់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ឬ ឱ្យកូនបំណុលទាំងអស់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់។

– សោហ៊ុយដើម្បីរក្សាជីវភាពឬមរបស់ប្ដីប្រពន្ធ និង សោហ៊ុយដើម្បីការអប់រំ ឬ ការព្យាបាល ថែទាំកូនជាអាទិ៍។

– កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្ដីប្រពន្ធទាំងសងខាងបានព្រមព្រៀងគ្នាតាមលិខិតជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុលនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្ដីប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយលក្ខណ៍អក្សរពីប្រពន្ធ ឬ ប្ដីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

– សោហ៊ុយដើម្បីគ្រប់គ្រង និង រក្សាទ្រព្យសម្បត្តិរួម។[33]

ដូចនេះ ក្នុងករណីនេះ ម្ចាស់បំណុលអាចទាមទារពីប្ដី ឬ ប្រពន្ធតែម្ខាងក៏បាន ឬ ទាមទារពីសហព័ទ្ធទាំងសងខាងក៏បានដែរ អាស្រ័យទៅតាមការជ្រើសរើសរបស់ម្ចាស់បំណុល។

- **កាតព្វកិច្ចផ្សេងទៀតរួមមាន៖**

– ការខ្ចីប្រាក់ដោយសហព័ទ្ធតែម្ខាង ដោយសហព័ទ្ធម្ខាងទៀតពុំមានការយល់ព្រម ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនរបស់សហព័ទ្ធនោះ។

– កាតព្វកិច្ចដែលបានកើតឡើង ដោយសារតែអំពើផ្ទាល់ខ្លួនរបស់សហព័ទ្ធម្ខាង។

– កាតព្វកិច្ចដែលកើតឡើងពីការទទួលខុសត្រូវរបស់សហព័ទ្ធម្ខាង ក្នុងនាមជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន។

– កាតព្វកិច្ចដែលកើតឡើងដោយសារតែការគ្រប់គ្រង ថែរក្សាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ។

ក្នុងករណីនេះ ប្រសិនបើកាតព្វកិច្ចខាងលើមិនត្រូវបានចាត់ចូលជាកាតព្វកិច្ចដោយសាមគ្គីរវាងសហព័ទ្ធ ឬ ដើម្បីតែផលប្រយោជន៍ឯកជនរបស់សហព័ទ្ធតែម្ខាង នោះសហព័ទ្ធណាម្នាក់នោះត្រូវទទួលបន្ទុកតែម្នាក់ឯងប៉ុណ្ណោះ។

### ខ- កាតព្វកិច្ចដែលកើតឡើងមុនពេលមានចំណងអាពាហ៍ពិពាហ៍

បន្ថែមពីនេះទៅទៀតនោះ ក្នុងករណីខ្លះ មុនពេលមានចំណងអាពាហ៍ពិពាហ៍ជាមួយសហព័ទ្ធម្ខាង សហព័ទ្ធម្ខាងទៀតបានជាប់នូវកាតព្វកិច្ច ឬ ទទួលបន្ទុកបំណុល ចំពោះម្ចាស់បំណុលរួចស្រេចទៅហើយ។ ដូចច្នេះ សហព័ទ្ធដែលជាប់កាតព្វកិច្ច គឺជាអ្នកទទួលបន្ទុកកាតព្វកិច្ចតែម្នាក់ឯង។ យ៉ាងណាមិញ បញ្ហាដែលអាចចោទឡើងគឺថា តើម្ចាស់ម្ចាស់បំណុលអាចធ្វើការទាមទារឱ្យអនុវត្តចំពោះទ្រព្យសម្បត្តិរួមដែរឬទេ? ក្នុងករណីនេះ ការអនុញ្ញាតឱ្យម្ចាស់បំណុលស្នើសុំទាមទារឱ្យអនុវត្តចំពោះទ្រព្យសម្បត្តិរួមដើម្បីធ្វើការទូទាត់លើបំណុលរបស់សហព័ទ្ធណាម្ខាង

[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧៥។

គឺជាការសមរម្យ កាលណា នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ សហព័ទ្ធតែម្ខាងនោះបានរួមចំណែកក្នុងការបង្កើតឡើងនូវទ្រព្យសម្បត្តិរួមនោះជាមួយសហព័ទ្ធម្ខាងទៀត។

## ១.២- ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិសង្វាសជន

ទោះជាអនីតិសង្វាសពុំត្រូវបានទទួលស្គាល់ដោយច្បាប់ជាធរមានក៏ដោយ ក៏វានៅតែមានរបបគតិយុត្តផ្នែកទ្រព្យសម្បត្តិរបស់វាផ្ទាល់ផងដែរ។ ដូចនេះ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិសង្វាសអាចត្រូវបានគេបកស្រាយដោយស្ថិតក្រោមរូបភាពពីរ គឺការអនុវត្តតាមរបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលកំណត់ដោយច្បាប់ (១.២.១) និង ការអនុវត្តតាមបញ្ញត្តិអំពីកម្មសិទ្ធិអវិភាគ (១.២.២)។

### ១.២.១- ការអនុវត្តតាមរបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលកំណត់ដោយច្បាប់

ក្នុងករណីនេះ ការអនុវត្តតាមរបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលកំណត់ដោយច្បាប់ សំដៅទៅលើការអនុវត្តតាមគោលការណ៍ទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ ដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី។ ដូចគ្នានឹងសហព័ទ្ធ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិសង្វាសជនត្រូវបានទទួលស្គាល់ ឬ អនុលោមតាមគោលការណ៍នេះ។[34] ជាពិសេស នៅពេលមានបណ្តឹងធ្វើឡើងដោយអនីតិសង្វាសជនទាមទារឱ្យធ្វើការបែងចែកទ្រព្យសម្បត្តិទៅតុលាការ គេឃើញថាគោលការណ៍ទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែកត្រូវបានយកមកធ្វើជាគោលការណ៍ដើម្បីដោះស្រាយក្តីផងដែរ។[35, 36] ដូចនេះ ទ្រព្យសម្បត្តិដោយឡែករបស់អនីតិសង្វាសជន គឺជាទ្រព្យសម្បត្តិដែលភាគីនៃអនីតិសង្វាសជនមាន ឬ ទទួលបាននៅមុនពេលដែលចំណងបែបអនីតិសង្វាសត្រូវបានបង្កើតឡើង។ ជាមួយគ្នានេះ ទ្រព្យសម្បត្តិរួមរបស់អនីតិសង្វាស គឺជាទ្រព្យសម្បត្តិដែលកើតឡើងនៅក្រោយពេលអនីតិសង្វាសជនមានជីវភាពរួមគ្នា ឬ ចាប់ផ្តើមរស់នៅជាប្តីប្រពន្ធលក្ខណៈជាអនីតិសង្វាស។

ទន្ទឹមនឹងគ្នានេះ ដោយសារមាត្រានៃទ្រព្យសម្បត្តិរួម (មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី) ត្រូវបានយកមកអនុវត្តក្នុងអនីតិសង្វាស នោះមាត្រាពាក់ព័ន្ធផ្សេងទៀតដូចជា មាត្រាស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និង ការចាត់ចែងទ្រព្យសម្បត្តិរួម (មាត្រា ៩៧៤ មាត្រា ៩៧៦ និងមាត្រា ៩៧៧ នៃក្រមរដ្ឋប្បវេណី) ក៏អាចយកមកអនុវត្តបានផងដែរ។ ជាពិសេស មាត្រាស្តីពីការទទួលខុសត្រូវដោយសាមគ្គីរវាងប្តីប្រពន្ធ (មាត្រា ៩៧៥ នៃក្រមរដ្ឋប្បវេណី) ដោយសារតែស្ថានភាពទាំងពីរមានទំនាក់ទំនងគ្នាយ៉ាងខ្លាំង ពោលគឺ ប្រសិនបើទ្រព្យសម្បត្តិដែលត្រូវបានទិញ

[34] ក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៧, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ៣*, ទំព័រ៣០។

[35] ក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៧, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ៣*, ទំព័រ៣០។

[36] ឧបសម្ព័ន្ធទី២៖ សាលាឧទ្ធរណ៍, សាលដីកាលេខ ០២ (គ) ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩, *រឿងក្តីរដ្ឋប្បវេណីលេខ ៣៦៥ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩*, សំអាងហេតុ ចំណុចទី២។

ក្លាយជាទ្រព្យរួម នោះកាតព្វកិច្ចនៃការបង់សោហ៊ុយលើការទិញទ្រព្យសម្បត្តិនោះ គួរតែជាការទទួលខុសត្រូវដោយសាមគ្គីភាពផងដែរ។[37]

## ១.២.២- ការអនុវត្តតាមបញ្ញត្តិអំពីកម្មសិទ្ធិអវិភាគ

ផ្ទុយពីករណីខាងលើនេះ បើតាមបំណកស្រាយផ្សេងទៀត ជាគោលការណ៍ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធមិនមានអានុភាពលើចំណងអនីតិសង្វាសនោះទេ ហើយទ្រព្យរួមក៏មិនអាចកើតឡើងរវាងបុគ្គលនៃចំណងអនីតិ-សង្វាសផងដែរ ពោលគឺទំនាក់ទំនងទ្រព្យសម្បត្តិនៃអនីតិសង្វាសមិនស្ថិតនៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនោះទេ ដោយមូលហេតុថា ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធអនុវត្តបានចំពោះតែសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ប៉ុណ្ណោះ ហើយទ្រព្យរួមកើតមានឡើងលុះត្រាតែមានអាពាហ៍ពិពាហ៍ស្របច្បាប់ប៉ុណ្ណោះ។ ដូចនេះ ក្នុងករណីនេះ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិសង្វាសជនអាចអនុវត្តតាមបញ្ញត្តិអំពីកម្មសិទ្ធិអវិភាគ។[38] ក្នុងនោះ ចំណែកទ្រព្យសម្បត្តិរបស់អនីតិសង្វាសមិនអាចបែងចែកបាន ឬ មិនមានភាពច្បាស់លាស់ នោះគេអាចកំណត់បានថាទ្រព្យទាំងនោះជាទ្រព្យនៃកម្មសិទ្ធិអវិភាគ[39] ដែលជាគោលការណ៍ បទប្បញ្ញត្តិនេះអាចត្រូវយកមកដោះស្រាយក្នុងករណីមានវិវាទក្នុងការប្រើប្រាស់ទ្រព្យ ឬ មិនអាចព្រមព្រៀងគ្នាលើការគ្រប់គ្រង និងថែទាំទ្រព្យទាំងនោះបាន។[40] ដូច្នេះ តើអ្វីជាកម្មសិទ្ធិអវិភាគ (**១.២.២.១**)? តើការប្រើប្រាស់ ថែទាំ និងគ្រប់គ្រងវត្ថុនៃកម្មសិទ្ធិអវិភាគមានលក្ខណៈដូចម្តេច (**១.២.២.២**)? ហើយ តើវត្ថុនៃកម្មសិទ្ធិអវិភាគត្រូវបានចាត់ចែងយ៉ាងដូចម្តេច (**១.២.២.៣**)? និង តើម្ចាស់កម្មសិទ្ធិអវិភាគមានបន្ទុកអ្វីខ្លះចំពោះវត្ថុនៃកម្មសិទ្ធិអវិភាគ (**១.២.២.៤**)?

### ១.២.២.១- សញ្ញាណនៃកម្មសិទ្ធិអវិភាគ

កម្មសិទ្ធិអវិភាគ គឺជាស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួនដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ។[41] យោងតាមនិយមន័យនេះ ម្ចាស់កម្មសិទ្ធិអវិភាគអាចអនុវត្តនូវចំណែករបស់ខ្លួនបានដោយសេរី ប្រសិនបើវាមិនមានផលប៉ះពាល់ដល់ចំណែករបស់អ្នកដទៃ។ ប៉ុន្តែ បើការអនុវត្តសិទ្ធិនេះប៉ះពាល់ដល់ម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀត ការអនុវត្តនេះមិនអនុញ្ញាតឱ្យអនុវត្តដោយសេរីបានទេ។[42]

---

[37] ក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៧, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ៣*, ទំព័រ៣១។

[38] ចក សម្បត្តិ, ២០១៤, *អនីតិសង្វាសជន*, ទំព័រ៤៩។

[39] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ២០២។

[40] ចក សម្បត្តិ, ២០១៤, *អនីតិសង្វាសជន*, ទំព័រ៥០។

[41] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ២០២។

[42] ក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៣, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ១*, ទំព័រ៧៩។

លើសពីនេះ តើចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគត្រូវបានកំណត់យ៉ាងដូចម្តេច? ចំណែក គឺជាឯកតានៃតម្លៃស្មើគ្នាដែលនៅក្នុងនោះ វត្ថុត្រូវបានបែងចែក។ យោងតាមមាត្រា ២០៣ ចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗត្រូវបានសន្មតថាស្មើគ្នា ដែលការណ៍នេះជាការសន្មត ក្នុងករណីដែលពុំមានការកំណត់លំអិតអំពីចំណែកនៃកម្មសិទ្ធិអវិភាគ។ **<u>ឧទាហរណ៍</u>** **ក ខ គ** និង **ឃ** គឺជាម្ចាស់កម្មសិទ្ធិអវិភាគលើដីមួយកន្លែង។ ផ្អែកតាមមាត្រា ២០៣ ម្នាក់ៗមានចំណែក ២៥% (សន្មត) មានន័យថា ចំណែកស្មើៗគ្នានេះគឺគ្រាន់តែជាការសន្មតប៉ុណ្ណោះ។ ប៉ុន្តែ **ក ខ គ** និង **ឃ** អាចធ្វើការសន្យាពិសេស ដោយឧបមាបានថា **ក** មាន៤០% **ខ គ** និង **ឃ** មាន២០%ដូចគ្នា។ លើសពីនេះទៀតនោះ ក្នុងករណី **ខ** ស្លាប់ តែ **ខ** មានកូនពីរនាក់គឺ **ខ១** និង **ខ២** នោះ **ខ១** និង **ខ២** នឹងបន្តការចែកចំណែករបស់ **ខ** ដែលជាលទ្ធផល គឺ **ខ១** មាន១០% និង **ខ២** មាន១០%។[43]

**១.២.២.២- ការប្រើប្រាស់ ថែទាំ និងគ្រប់គ្រងវត្ថុនៃកម្មសិទ្ធិអវិភាគ**

យោងតាមមាត្រា ២០៥ ម្ចាស់កម្មសិទ្ធិអវិភាគ អាចប្រើប្រាស់វត្ថុកម្មសិទ្ធិអវិភាគទាំងមូល តាមសមាមាត្រនៃចំណែករបស់ខ្លួន។ ជាមួយគ្នានេះ ម្ចាស់កម្មសិទ្ធិក៏អាចធ្វើការកំណត់លំអិតអំពីវិធីប្រើប្រាស់ដោយការពិភាក្សាគ្នាផងដែរ។ **<u>ឧទាហរណ៍</u>** រថយន្តមួយមាន **ក ខ** និង **គ** ជាម្ចាស់ដែលជាកម្មសិទ្ធិអវិភាគដោយ **ក** មានចំណែក៥ **ខ** មានចំណែក១ និង **គ** មានចំណែក១។ បើភាគីទាំងអស់ព្រមព្រៀងគ្នាប្រើប្រាស់ចំណែកជា **ថ្ងៃក្នុងមួយសប្តាហ៍** នោះចំណែករបស់ **ក** គឺមាន ៥/៧ ចំណែករបស់ **ខ** គឺមាន ១/៧ និង ចំណែករបស់ **គ** គឺមាន ១/៧។ ដូចនេះ វិធីនៃការប្រើប្រាស់ គឺ៖

- **ក** មានសិទ្ធិប្រើប្រាស់បានចំនួន ៥ថ្ងៃ ក្នុងមួយសប្តាហ៍
- **ខ** មានសិទ្ធិប្រើប្រាស់បានចំនួន ១ថ្ងៃ ក្នុងមួយសប្តាហ៍
- **គ** មានសិទ្ធិប្រើប្រាស់បានចំនួន ១ថ្ងៃ ក្នុងមួយសប្តាហ៍។

ចំពោះការថែទាំវិញ យោងតាមមាត្រា ២០៦ ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ អាចធ្វើសកម្មភាពថែទាំវត្ថុកម្មសិទ្ធិអវិភាគដោយឯកឯងបាន ដែលការថែទាំនោះអាចជា ការជួសជុល ជាដើម។ ក្នុងនោះ ការថែរក្សាវត្ថុកម្មសិទ្ធិអវិភាគ គឺម្នាក់ៗអាចធ្វើបានដោយពុំចាំបាច់មានការព្រមព្រៀងជាមួយម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀតឡើយ ដោយសារវាមិនមានផលប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃឡើយ។

[43] ក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៣, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១*, ទំព័រ៨០។

ចំណែកការគ្រប់គ្រងវិញ ត្រូវសម្រេចដោយមតិភាគច្រើនតាមតម្លៃនៃចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ ចំពោះកិច្ចការទាំងឡាយដែលទាក់ទងនឹងការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគ បើយោងតាមមាត្រា ២០៨។ សកម្មភាពគ្រប់គ្រងនេះអាចជា ការជួលជាបណ្ដោះអាសន្ន ឬ សកម្មភាពបង្កើនតម្លៃនៃវត្ថុកម្មសិទ្ធិអវិភាគដែលមិនសូវសំខាន់ (ដីដែលធ្វើឱ្យរាបស្មើ ឬ ការផ្លាស់ប្ដូរ) ជាដើម។

**១.២.២.៣- ការចាត់ចែងវត្ថុនៃកម្មសិទ្ធិអវិភាគ**

ក្នុងករណីនេះ ការចាត់ចែងលើវត្ថុកម្មសិទ្ធអវិភាគ អាចជាការចាត់ចែងចំណែករបស់ម្ចាស់កម្មសិទ្ធិខ្លួនឯង ឬ ការចាត់ចែងលើវត្ថុកម្មសិទ្ធិអវិភាគទាំងស្រុង។ យោងតាមមាត្រា ២០៤ ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗអាចចាត់ចែងចំណែកនៃកម្មសិទ្ធិអវិភាគរបស់ខ្លួនបានដោយពុំចាំបាច់មានការយល់ព្រមពីសំណាក់ម្ចាស់កម្មសិទ្ធិអវិភាគផ្សេងនោះទេ។ ការចាត់ចែងក្នុងករណីនេះអាចជា ការធ្វើអនុប្បទាន[44] ឬ ការដាក់ប្រាតិភោគ[45]នូវចំណែក ព្រមទាំងការបោះបង់សិទ្ធិនៃចំណែក (មាត្រា ២១០) ផងដែរ។ **ឧទាហរណ៍** **ក ខ គ** និង **ឃ** គឺជាម្ចាស់កម្មសិទ្ធិអវិភាគលើដីមួយកន្លែង។ **ក ខ គ** និង **ឃ** បានធ្វើការព្រមព្រៀងក្នុងចំណែកដោយ **ក** មាន៤០% **ខ** **គ** និង **ឃ** មាន ២០%ដូចគ្នា។ លើសពីនេះ ក្នុងករណី **ខ** ស្លាប់ តែ **ខ** គ្មានសន្តតិជន ឬ **ខ** បានបោះបង់ចំណែកខ្លួន គឺ **ក គ** និង **ឃ** នឹងត្រូវទទួលបានចំណែកពី **ខ** តាមសមាមាត្រនៃចំណែក **ក គ** និង **ឃ** ស្មើៗគ្នា ដោយ **ក** នឹងទទួលបាន ១០% រីឯ **ក** និង **ឃ** ទទួលបានម្នាក់ ៥%។ ម៉្យាងទៀត បើ **ខ** ផ្ទេរទ្រព្យសម្បត្តិនោះទៅឱ្យ **ក** គឺ **ខ** ពុំចាំបាច់ត្រូវទទួលការយល់ព្រមពី **គ** និង **ឃ** ដើម្បីបោះបង់ ឬ ផ្ទេរនោះទេ។ ហេតុនេះហើយទើបរាល់ចំណាត់ការទ្រព្យសម្បត្តិណាមួយរបស់ **ខ** គឺពុំចាំបាច់ឱ្យអ្នកដទៃយល់ព្រមនោះទេ។

ផ្ទុយទៅវិញ ប្រសិនបើវាជាការចាត់ចែងលើវត្ថុកម្មសិទ្ធិអវិភាគទាំងស្រុង ត្រូវមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ ដោយយោងតាមមាត្រា ២០៧។ **ឧទាហរណ៍** **ក ខ** និង **គ** ជាម្ចាស់កម្មសិទ្ធិអវិភាគលើរថយន្តមួយ ហើយ **ក** ចង់លក់រថយន្តឱ្យទៅ **ឃ** ដែលបានតម្លៃខ្ពស់។ ប៉ុន្តែ **ខ** និង **គ** ពុំឯកភាពជាមួយ **ក** ទេ។ ដូចនេះរថយន្តនេះពុំអាចលក់បានឡើយ លុះត្រាតែមានការព្រមព្រៀងជាមួយកម្មសិទ្ធិករអវិភាគផ្សេងទៀត ដើម្បីការពារដល់ម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀត។

[44] អនុប្បទាន គឺការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ ដែលជាអនុប្បទាយីទៅឱ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក។

[45] ប្រាតិភោគ គឺ ១-ការធានាដល់ម្ចាស់បំណុលក្នុងការប្រមូលឥណទេយ្យរបស់ខ្លួនមកវិញ។ ២-មធ្យោបាយមួយដើម្បីធានាការសងកាតព្វកិច្ច។

### ១.២.២.៤- បន្ទុករបស់ម្ចាស់កម្មសិទ្ធិអវិភាគចំពោះវត្ថុនៃកម្មសិទ្ធិអវិភាគ[46]

ក្រៅពីផលប្រយោជន៍ដែលទទួលបាន ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗត្រូវទទួលបន្ទុកក្នុងការបង់សោហ៊ុយគ្រប់គ្រង ពន្ធដារ ជាអាទិ៍ តាមសមាមាត្រនៃចំណែករៀងៗខ្លួន។ ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់បានបង់សោហ៊ុយដើម្បីការថែទាំ គ្រប់គ្រង ឬ បន្ទុកផ្សេងទៀតដែលលើសពីបន្ទុករបស់ខ្លួន ម្ចាស់កម្មសិទ្ធិអវិភាគនោះអាចទាមទារឲ្យម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀតសងប្រាក់ដែលខ្លួនបានបង់លើសនោះ តាមសមាមាត្រនៃចំណែករៀងៗខ្លួនបាន។ ហើយ សិទ្ធិទាមទារសងសោហ៊ុយនេះ ក៏អាចអនុវត្តបានដែរ ចំពោះជនដែលបានទទួលបន្តនូវចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគផ្សេង។

[46] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ២០៩។

# ជំពូកទី២

# ការបញ្ចប់នៃការ

# គ្រប់គ្រងទ្រព្យសម្បត្តិ

# របស់ប្តីប្រពន្ធ

# ជំពូកទី២

# ការបញ្ចប់នៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ

បន្ទាប់ពីក្លាយជាប្តីប្រពន្ធដែលអាចស្ថិតក្រោមស្ថានភាពជាសហព័ទ្ធ ឬ អនីតិសង្វាស នោះទំនាក់ទំនងទ្រព្យសម្បត្តិរវាងភាគីនឹងកើតឡើង។ លើសពីនេះទៀតនេះ សញ្ញាណនៃទ្រព្យសម្បត្តិ ក៏ដូចជាការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ បានបង្ហាញពីខាងលើរួចមក។ ដូចនេះ តើការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រូវបានបញ្ចប់ដោយរបៀបណាខ្លះ? នៅក្នុងចំណុចនេះ នឹងបកស្រាយទៅលើការបញ្ចប់ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ពោលគឺការបញ្ចប់នៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ **(២.១)** និង ការបញ្ចប់នៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិសង្វាសជន **(២.២)**។

## ២.១- ការបញ្ចប់នៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ

ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលដែលចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធត្រូវបានកាត់ផ្តាច់ ដែលការកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍នេះនឹងមានអានុភាពនាំឱ្យមានការបែងចែកទ្រព្យសម្បត្តិរវាងសហព័ទ្ធ។ ក្នុងនោះ ការកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍ស្ថិតក្រោមមូលហេតុមួយចំនួនរួមមាន៖ ការលែងលះ **(២.១.១)** និង មរណភាពនិងការប្រកាសអំពីការបាត់ខ្លួន **(២.១.២)**។[47]

### ២.១.១- ការលែងលះ

ការលែងលះ គឺជាការរំលាយចំណងអាពាហ៍ពិពាហ៍ ដែលមានពីរប្រភេទ គឺការលែងលះដោយមានការព្រមព្រៀង និង ការលែងលះដោយគ្មានការព្រមព្រៀង។ លើសពីនេះ វានឹងនាំឱ្យមានការបែងចែកទ្រព្យសម្បត្តិរវាងភាគីនៃអាពាហ៍ពិពាហ៍នោះ។

#### ២.១.១.១- ប្រភេទនៃការលែងលះ

##### ក- ការលែងលះដោយមានការព្រមព្រៀង

ប្រសិនបើភាគីនៃអាពាហ៍ពិពាហ៍ (សហព័ទ្ធ) បានព្រមព្រៀងគ្នាថា ពួកគេមិនអាចរួមរស់នៅជាមួយគ្នាតទៅទៀតបានទេ ពួកគេអាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបាន[48] ដែលនេះបញ្ជាក់ពីគោលការណ៍ស្ម័គ្រចិត្តក្នុងការលែងលះរវាងភាគីនៃអាពាហ៍ពិពាហ៍។[49] ក្នុងករណីនេះ បើតុលាការរកឃើញថា ភាគីមានឆន្ទៈព្រមព្រៀង

[47] ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦, មាត្រា ៣ កថាខណ្ឌទី២។
[48] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧៩។
[49] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ, លេខ ៥៦ ក្រ, ២០ កក្កដា ១៩៨៩, មាត្រា ៤០។

គ្នាពិតប្រាកដក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ តុលាការត្រូវតែសម្រេចឱ្យភាគីលែងលះគ្នាតាមដីកាសម្រេចលែងលះ។[50]

**ខ- ការលែងលះដោយគ្មានការព្រមព្រៀង**

ប្រសិនបើ ភាគីនៃអាពាហ៍ពិពាហ៍មិនមានឆន្ទៈព្រមព្រៀងគ្នាក្នុងការលែងលះទេ ភាគីប្ដី ឬ ប្រពន្ធអាចដាក់ពាក្យបណ្ដឹងលែងលះគ្នាទៅតុលាការបាន ដែលមូលហេតុនៃការលែងលះគ្នាត្រូវស្របតាមមាត្រា ៩៧៨ ៖

ក. បើបានប្រព្រឹត្តអំពើផិត[51] ទៅលើសហព័ទ្ធ។

ខ. បើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ។

គ. បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់ អស់រយៈពេលជាង ១ ឆ្នាំ។

ឃ. បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍។

ង. ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។

**២.១.១.២- ការបែងចែកទ្រព្យសម្បត្តិ**

ការលែងលះមិនត្រឹមតែបានកាត់ផ្ដាច់នូវចំណងអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ តែក៏ជះឥទ្ធិពលទៅលើការបែងចែកទ្រព្យសម្បត្តិ សិទ្ធិអំណាចក្នុងការគ្រប់គ្រងថែរក្សាកូន សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗក្រោយលែង-លះ ព្រមទាំងឋានៈបុគ្គល និងបញ្ហាផ្សេងៗទៀត។ ក្នុងនោះ ចំពោះការបែងចែកទ្រព្យសម្បត្តិ ប្រសិនបើប្ដីប្រពន្ធលែងលះបានពិភាក្សា និងមានការព្រមព្រៀងគ្នាលើការបែងចែកជាក់លាក់បែបណាមួយក្រោយពីពួកគេបានបញ្ជាក់អំពីទំហំ ប្រភេទ និង តម្លៃនៃទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក ការព្រមព្រៀងនោះត្រូវតែទទួលការគោរព ហើយការបែងចែកទ្រព្យនោះត្រូវឈរលើគោលការណ៍យុត្តិធម៌។[52] ម៉្យាងទៀត ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្ដីប្រពន្ធបានទេ ការបែងចែកទ្រព្យសម្បត្តិត្រូវផ្អែកតាមចំណុចនីមួយៗដូចកំណត់ខាងក្រោម៖

១- សហព័ទ្ធនីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនរៀងៗខ្លួន ហើយនិង

២- ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែ បើមានករណីពិសេស និង មានការទាមទាររបស់ប្ដីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគ

[50] ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា ៣ កថាខណ្ឌទី២។

[51] ផិត គឺការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្ដីរបស់ខ្លួន (មាត្រា ៧ នៃច្បាប់ស្ដីពីឯកពន្ធភាព)។

[52] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨០ កថាខណ្ឌទី១។

របស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគិនីមួយៗ និង ផលប្រយោជន៍របស់កូនជាអាទិ៍។ គួរបញ្ជាក់ផងដែរថា ការងារគេហកិច្ច (ការងារក្នុងផ្ទះ) ត្រូវបានចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះផងដែរ។[53]

ទន្ទឹមនឹងគ្នានេះ នៅក្នុងរឿងលែងលះ ភាគីលែងលះតែងធ្វើបណ្តឹងសុំលែងលះ ព្រមទាំងភ្ជាប់មកជាមួយនូវបណ្តឹងសុំបែងចែកទ្រព្យសម្បត្តិ។ ក្នុងករណីនេះ តុលាការត្រូវសម្រេចពីការបែងចែកទ្រព្យឱ្យភាគី ដោយត្រូវពិនិត្យឱ្យច្បាស់ថា ភាគីបានដាក់ពាក្យសុំបែងចែកទ្រព្យដែរឬទេ។ ក្នុងករណីគ្មានពាក្យបណ្តឹងសុំបែងចែកទ្រព្យទេនោះ តុលាការមិនអាចវិនិច្ឆ័យអំពីការបែងចែកទ្រព្យបានឡើយ។ យ៉ាងណាមិញ ករណីខ្លះ គូភាគីប្តឹងសុំបែងចែកទ្រព្យក្រោយពេលលែងលះ ដោយអនុវត្តតាមនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

### ២.១.២- មរណភាពនិងការប្រកាសអំពីការបាត់ខ្លួន

ដូចបានបញ្ជាក់នៅខាងលើ មរណភាពនិងការប្រកាសអំពីការបាត់ខ្លួន ក៏ជាមូលហេតុដែលនាំឱ្យអាពាហ៍-ពិពាហ៍មួយត្រូវកាត់ផ្តាច់ដែរ ហើយការណ៍នេះក៏នាំទៅរកការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធផងដែរ។

#### ២.១.២.១- អំពីមរណភាព និងការប្រកាសអំពីការបាត់ខ្លួន

មរណភាពរបស់សហព័ទ្ធណាម្ខាង ក៏ជាមូលហេតុមួយ ក្នុងការឈានទៅដល់ការបញ្ចប់ចំណងអាពាហ៍ពិពាហ៍មួយផងដែរ។ ហើយ ក្នុងករណីខ្លះ សហព័ទ្ធណាម្ខាងបានអវត្តមានដោយពុំមានដំណឹងច្បាស់លាស់ថា នៅរស់ ឬ ទទួលមរណភាព ក្នុងអំឡុងពេល៖

១- ៥ ឆ្នាំ ឬ

២- ១ ឆ្នាំ ក្រោយពីចូលទៅតំបន់ដែលមានសង្គ្រាម នៅក្នុងនាវាដែលបានលិច ឬ បានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព នោះតុលាការអាចប្រកាសបានថា សហព័ទ្ធដែលអវត្តមាននោះបានបាត់ខ្លួន តាមពាក្យសុំរបស់សហព័ទ្ធម្ខាងទៀត អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬ អ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន។[54] ក្នុងនោះ អានុភាពនៃការប្រកាស

[53] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨០ កថាខណ្ឌទី២-៣។
[54] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៤១។

អំពីការបាត់ខ្លួន នឹងនាំឱ្យសហព័ទ្ធដែលអវត្តមាន (អ្នកបាត់ខ្លួន) ត្រូវបានចាត់ទុកថាបានទទួលមរណភាព។[55] ដូចនេះ ក្នុងករណីនេះ ចំណងអាពាហ៍ពិពាហ៍ក៏ត្រូវបានបញ្ចប់ដែរ។

**២.១.២.២- អំពីការបែងចែកទ្រព្យសម្បត្តិ**

ក្នុងករណីនេះ សហព័ទ្ធដែលនៅរស់នឹងទទួលបាននូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន។ បន្ថែមពីនេះ សហព័ទ្ធដែលនៅរស់នឹងទទួលបានពាក់កណ្ដាលនៃទ្រព្យសម្បត្តិរួមទៀត។ រីឯ ទ្រព្យសម្បត្តិដោយឡែក និង ទ្រព្យសម្បត្តិរួមពាក់កណ្ដាលរបស់សហព័ទ្ធដែលទទួលមរណភាព នឹងក្លាយជាកម្មវត្ថុនៃសន្តតិកម្ម។

## ២.២- ការបញ្ចប់នៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិសង្វាសជន

ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិសង្វាសជននឹងត្រូវបញ្ចប់ កាលណាអនីតិសង្វាសត្រូវបានរំលាយដោយមូលហេតុចំនួន បី រួមមាន៖ ការបង្កើតអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ (២.២.១) ការព្រមព្រៀងគ្នាបញ្ចប់ទំនាក់ទំនងអនីតិសង្វាស (២.២.២) និង មរណភាពនិងការប្រកាសអំពីការបាត់ខ្លួន (២.២.៣)។ បន្ថែមពីលើនេះ អានុភាពនៃការបញ្ចប់ ក៏ត្រូវបានលើកយកមកបង្ហាញក្នុងករណីនីមួយៗផងដែរ។

### ២.២.១- ការបង្កើតអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់

**២.២.១.១- អំពីការបង្កើតអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់**

អនីតិសង្វាសនឹងត្រូវបានរំលាយ នៅពេលភាគីនៃអនីតិសង្វាសព្រមព្រៀងគ្នាក្នុងការបង្កើតអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ ដើម្បីអាចឱ្យអាពាហ៍ពិពាហ៍ត្រូវបានទទួលស្គាល់និងមានចំណងគតិយុត្តតាមផ្លូវច្បាប់ ភាគីនៃអាពាហ៍ពិពាហ៍ត្រូវបំពេញលក្ខខណ្ឌនៃអាពាហ៍ពិពាហ៍ដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី[56] ពោលគឺ ត្រូវបំពេញលក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់ នៃអាពាហ៍ពិពាហ៍។ ជាពិសេស ក្នុងលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍ ភាគីត្រូវតែចុះសំបុត្រអាពាហ៍ពិពាហ៍នៅមុខមន្ត្រីអត្រានុកូលដ្ឋាន[57] បើពុំដូច្នោះទេ ច្បាប់មិនទទួលស្គាល់អាពាហ៍ពិពាហ៍នោះឡើយ ហើយទំនាក់ទំនងអនីតិសង្វាសក៏មិនត្រូវបានរំលាយដែរ។

**២.២.១.២- អំពីអានុភាពនៃការរំលាយអនីតិសង្វាសតាមរយៈអាពាហ៍ពិពាហ៍**

នៅពេលអនីតិសង្វាសត្រូវបានរំលាយ ហើយភាគីនៃអនីតិសង្វាសបានចុះសំបុត្រអាពាហ៍ពិពាហ៍រួចរាល់ នោះភាគី ឬ អនីតិសង្វាសជននោះនឹងទទួលបានឋានៈជាសហព័ទ្ធ និង បង្កើតឱ្យមានសិទ្ធិ និងករណីយកិច្ចទាំងក្នុងទំនាក់ទំនងបុគ្គល ទាំងក្នុងទំនាក់ទំនងទ្រព្យសម្បត្តិ ដូចដែលបានកំណត់ក្នុងច្បាប់។ គួរបញ្ជាក់ផងដែរថា ទ្រព្យសម្បត្តិដែលបានកើតមានក្នុងអំឡុងពេលអនីតិសង្វាស ពុំត្រូវបានកំណត់ច្បាស់លាស់ដោយច្បាប់ឡើយ

[55] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៤៣។

[56] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, គន្ថីទី ៧ ជំពូកទី ៣ ផ្នែកទី ១ កថាខណ្ឌទី ១ មាត្រា ៩៤៨-៩៥៧។

[57] អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០, មាត្រា ៣០។

ហើយជាក់ស្តែង អនីតិសង្វាសជនធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិនោះដោយស្ថិតក្រោមបំណកស្រាយពីរ គឺករណីអនុវត្តតាមរបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលកំណត់ដោយច្បាប់ និង ករណីអនុវត្តតាមបញ្ញត្តិអំពីកម្មសិទ្ធិអវិភាគ។ ប៉ុន្តែ បន្ទាប់ពីមានអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ទ្រព្យសម្បត្តិដែលបានកើតមានក្នុងអំឡុងពេលអនីតិសង្វាសនោះ នឹងត្រូវបានច្បាប់កំណត់ច្បាស់លាស់ និងការពារ ហើយក៏អាចឱ្យសហព័ទ្ធជ្រើសរើសដោយសេរីនូវប្រព័ន្ធគ្រប់គ្រងលើទ្រព្យសម្បត្តិនោះផងដែរ ដែលរួមមានប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមកិច្ចសន្យា និង ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់កំណត់។

## ២.២.២- ការព្រមព្រៀងគ្នាបញ្ចប់ទំនាក់ទំនងអនីតិសង្វាស

### ២.២.២.១- អំពីការព្រមព្រៀងគ្នាបញ្ចប់ទំនាក់ទំនងអនីតិសង្វាស

ផ្ទុយពីការរំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ដែលត្រូវតែមានដីកាសម្រេច ឬ សាលក្រមរបស់តុលាការ ការរំលាយអនីតិសង្វាសមិនត្រូវការសេចក្តីសម្រេចរបស់តុលាការឡើយ។ ទោះបីមានពាក្យបណ្តឹង ឬពាក្យសុំឱ្យរំលាយអនីតិសង្វាស ឬ សុំផ្តាច់អនីតិសង្វាស ឬ សុំបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍ក៏ដោយ ក៏ពាក្យបណ្តឹងនោះនឹងត្រូវលើកចោលដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ទេ ដោយហេតុថាបណ្តឹងមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបាន។[58] ដូចនេះ ការរំលាយអនីតិសង្វាសមិនតម្រូវឱ្យមានការអន្តរាគមន៍ពីតុលាការនោះទេ។ លើសពីនេះ យើងអាចនិយាយបានថាមាត្រានៃក្រមរដ្ឋប្បវេណីដែលចែងអំពីលក្ខខណ្ឌ និង នីតិវិធីនៃការលែងលះ ក៏មិនត្រូវបានយកមកអនុវត្តផងដែរ។[59] សរុបជារួមមក អនីតិសង្វាស ត្រូវរំលាយក្រោយពីភាគីបានព្រមព្រៀងគ្នាបញ្ចប់ទំនាក់ទំនងក្នុងការរស់នៅជាប្តីប្រពន្ធនោះ ដោយហេតុថា អនីតិសង្វាសជាព្រឹត្តិវិន័យ ឬ លក្ខណៈជាក់ស្តែង មិនមែនជាចំណងគតិយុត្តតាមផ្លូវច្បាប់ ដែលកើតឡើងតាមឆន្ទៈសេរីរបស់គូភាគីនៃអនីតិសង្វាស ដូចនេះវាក៏ត្រូវរំលាយទៅវិញតាមឆន្ទៈសេរីរបស់គូភាគីវិញដែរ។[60]

### ២.២.២.២- អំពីអានុភាពនៃការរំលាយអនីតិសង្វាសដោយការព្រមព្រៀងគ្នា

ក្នុងករណីនេះ អានុភាពនៃការរំលាយនឹងនាំឱ្យមានការបែងចែកទ្រព្យសម្បត្តិរវាងភាគីនៃអនីតិសង្វាស។ ជាក់ស្តែង ទោះបីជាតុលាការតែងតែច្រានចោលបណ្តឹងទាមទារផ្តាច់អនីតិសង្វាសរបស់ដើមចោទ ប៉ុន្តែតុលាការបែជាសម្រេចអំពីអំណាចមេបា ឬ ទ្រព្យសម្បត្តិ ជាដើម។[61] ក្នុងនោះ ចំពោះការបែងចែកទ្រព្យសម្បត្តិរបស់អនីតិ-

[58] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៨១។

[59] ចក សម្បត្តិ, ២០១៤, *អនីតិសង្វាសជន*, ទំព័រ៦១។

[60] ចក សម្បត្តិ, ២០១៤, *អនីតិសង្វាសជន*, ទំព័រ៦០។

[61] ចក សម្បត្តិ, ២០១៤, *អនីតិសង្វាសជន*, ទំព័រ៦០។

សង្វាសជន ការបែងចែកទ្រព្យនឹងត្រូវអនុវត្តតាមបំណកស្រាយក្នុងករណីអនុវត្តតាមរបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលកំណត់ដោយច្បាប់ ឬ ករណីអនុវត្តតាមបញ្ញត្តិនៃកម្មសិទ្ធិអវិភាគ។

**ក-ករណីអនុវត្តតាមរបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលកំណត់ដោយច្បាប់**

ក្នុងករណីនេះ ប្រសិនបើអនីតិសង្វាសត្រូវបានរំលាយ ទ្រព្យសម្បត្តិដែលកើតមានឡើងក្នុងអំឡុងពេលអនីតិសង្វាសនឹងត្រូវធ្វើការបែងចែកតាមបញ្ញត្តិនៃ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី។[62] ក្នុងនោះ ភាគីនៃអនីតិសង្វាសអាចពិភាក្សាគ្នាក្នុងការបែងចែកទ្រព្យសម្បត្តិដោយឈរលើគោលការណ៍យុត្តិធម៌ ដែលក្នុងនោះ ភាគីអាចបែងចែកទ្រព្យសម្បត្តិទៅជាទ្រព្យសម្បត្តិរួម ទ្រព្យសម្បត្តិដោយឡែករបស់ប្តី និង ទ្រព្យសម្បត្តិដោយឡែកប្រពន្ធ ដើម្បីងាយស្រួលក្នុងការបែងចែក។ [63] ជាមួយគ្នានេះដែរ ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងភាគីនៃអនីតិសង្វាសបានទេ ការបែងចែកទ្រព្យសម្បត្តិត្រូវផ្អែកតាមចំណុចនីមួយៗដូចកំណត់ខាងក្រោម៖

១- អនីតិសង្វាសជននីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនរៀងៗខ្លួន ហើយនិង

២- ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែ បើមានករណីពិសេស និង មានការទាមទាររបស់អនីតិសង្វាសជនណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូន ជាអាទិ៍។ គួរបញ្ជាក់ផងដែរថា ការងារគេហកិច្ច (ការងារក្នុងផ្ទះ) ត្រូវបានចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះផងដែរ។[64]

ដូចនេះ នៅពេលដែលមានបណ្តឹងទាមទារឱ្យបែងចែកទ្រព្យសម្បត្តិ តុលាការនឹងធ្វើការសម្រេចតាមគោលការណ៍ខាងលើ ហើយចេញសេចក្តីសម្រេច ជាដីកាសម្រេចតាមនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។[65]

---

[62] ក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៧, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ៣*, ទំព័រ៣០។

[63] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨០ កថាខណ្ឌទី១។

[64] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨០ កថាខណ្ឌទី២-៣។

[65] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា ៣ កថាខណ្ឌទី២ និង ផ្នែកទី៤ ចំណុចទី៦ នៃតារាងឧបសម្ព័ន្ធ ។

**ខ-ករណីអនុវត្តតាមបញ្ញត្តិនៃកម្មសិទ្ធិអវិភាគ**

ក្នុងករណីនេះ នៅពេលទ្រព្យសម្បត្តិដែលកើតមានឡើងក្នុងអំឡុងពេលអនីតិសង្វាសត្រូវបានឡូកឡំគ្នា និងមិនអាចបែងចែកដាច់ពីគ្នាបាន ទ្រព្យសម្បត្តិទាំងនោះអាចចាត់ទុកជាទ្រព្យសម្បត្តិដែលមានគ្រប់គ្រងស្ថិត ក្រោមបញ្ញត្តិនៃកម្មសិទ្ធិអវិភាគ នៃក្រមរដ្ឋប្បវេណី។ ដូចបានបញ្ជាក់ខាងលើ កម្មសិទ្ធិអវិភាគ គឺជាស្ថានភាពដែលមានកម្មសិទ្ធិករច្រើននាក់ ហើយម្ចាស់កម្មសិទ្ធិអវិភាគអាចចាត់ចែងដោយសេរីនូវចំណែកនៃកម្មសិទ្ធិអវិភាគរបស់ខ្លួនដោយសេរីបានដូចដែលមានចែងក្នុងមាត្រា ២០៤។ ម្យ៉ាងទៀត ម្ចាស់កម្មសិទ្ធិអវិភាគនោះអាចរំលាយស្ថានភាពនៃកម្មសិទ្ធិអវិភាគនោះពេលណាក៏បាន ដែលសិទ្ធិទាមទាររំលាយស្ថានភាពកម្មសិទ្ធិអវិភាគនេះហៅថា សិទ្ធិទាមទារឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគ។[66] ក្នុងករណីដែលម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់បានអនុវត្តសិទ្ធិទាមទារឱ្យបែងចែក ជាគោលការណ៍ ម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ត្រូវធ្វើការពិភាក្សាគ្នា។ ប៉ុន្តែ ប្រសិនបើការពិភាក្សានោះមិនបានសម្រេច ឬ ម្ចាស់កម្មសិទ្ធិអវិភាគមួយចំនួនមិនព្រមធ្វើការពិភាក្សាគ្នា ម្ចាស់កម្មសិទ្ធិអាចដាក់ពាក្យបណ្តឹងទៅតុលាការទាមទារឱ្យបែងចែកបាន។[67]

ក្នុងករណីធ្វើការពិភាក្សាគ្នា ម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់អាចសម្រេចជ្រើសរើសវិធីបែងចែកណាមួយៈ

១- ការបែងចែកវត្ថុកម្មសិទ្ធិអវិភាគផ្ទាល់តែម្តង ដែលហៅថា**ការបែងចែកវត្ថុផ្ទាល់**។ **ឧទាហរណ៍** ការបែងចែកដីកម្មសិទ្ធិអវិភាគរបស់ **ក ខ** និង **គ** ជាបីឡូត៍ដាច់ៗពីគ្នា ហើយឱ្យអ្នកទាំងបីនោះមានកម្មសិទ្ធិលើដីនីមួយៗនោះ។

២- ការលក់វត្ថុកម្មសិទ្ធិអវិភាគទៅឱ្យតតិយជន ហើយបែងចែកថ្លៃលក់បាននោះឱ្យម្ចាស់កម្មសិទ្ធិអវិភាគ ដែលហៅថា**ការបែងចែកថ្លៃលក់**។

៣- ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ក្នុងចំណោមម្ចាស់កម្មសិទ្ធិទាំងអស់ ធ្វើលទ្ធកម្មវត្ថុទាំងមូល ហើយបង់ប្រាក់ទៅឱ្យម្ចាស់កម្មសិទ្ធិដទៃទៀត ដែលហៅថា**សំណងនៃតម្លៃចំណែក**។[68]

ក្នុងករណីដាក់ពាក្យបណ្តឹងទៅតុលាការ ជាគោលការណ៍ ការបែងចែកវត្ថុកម្មសិទ្ធិអវិភាគតាមផ្លូវបណ្តឹងត្រូវបែងចែកវត្ថុនោះផ្ទាល់តែម្តង។ ប៉ុន្តែ **ឧទាហរណ៍** ប្រសិនបើបែងចែកទៅ ទំហំដីនីមួយៗនោះតូចពេក ឬ តម្លៃដីធ្លាក់ខ្លាំងពេកទៅ អាចជ្រើសរើសយកវិធីបែកចែកដោយលក់ដីនោះ តាមការលក់ឡាយឡង់ ហើយបែងចែកថ្លៃលក់ទៅឱ្យម្ចាស់កម្មសិទ្ធិអវិភាគបាន។ ម្យ៉ាងទៀត **ឧទាហរណ៍** ក្នុងករណីនៃការបែកចែកដីស្រែចំការ ប្រសិនបើ

[66] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២១១។

[67] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២១២។

[68] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ២០០៩, *សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី១ : គន្ថីទី១-ទី៣*, ទំព័រ១៦៤។

យល់ឃើញថា គួរឱ្យម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ដែលមានឆន្ទៈបន្តការងារកសិកម្ម ធ្វើលទ្ធកម្មដីស្រែចំការនោះទាំងមូល ជាការល្អ។ ដូចនេះ ក្នុងករណីនេះ អាចជ្រើសរើសវិធីឱ្យម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ធ្វើលទ្ធកម្មដីទាំងមូល ហើយបង់ប្រាក់សំណងនោះ ចំពោះអ្នកដែលបានបាត់បង់ចំណែករបស់ខ្លួនបាន។[69]

គួរបញ្ជាក់ផងដែរថា ការដាក់ពាក្យបណ្ដឹងក្នុងករណីនេះ ត្រូវអនុលោមតាមនីតិវិធីរដ្ឋប្បវេណីធម្មតា នៃក្រមនីតិវិធីរដ្ឋប្បវេណី។

### ២.២.៣- មរណភាពនិងការប្រកាសអំពីការបាត់ខ្លួន

#### ២.២.៣.១- អំពីការមរណភាពនិងការប្រកាសអំពីការបាត់ខ្លួន

លើសពីនេះ អនីតិសង្វាសក៏អាចត្រូវរំលាយបានដែរ ដោយសារអនីតិសង្វាសជនណាម្ខាងបានទទួលមរណភាព និងប្រកាសអំពីការបាត់ខ្លួន ដែលត្រូវបានពន្យល់នៅក្នុងចំណុច **២.១.២.១**។

#### ២.២.៣.២- អំពីអានុភាពនៃការរំលាយអនីតិសង្វាសដោយមរណភាព

ក្នុងករណីនេះ អានុភាពនៃការរំលាយនឹងនាំឱ្យមានការបែងចែកទ្រព្យសម្បត្តិរបស់ភាគីនៃអនីតិសង្វាស ដែលការបែងចែកនេះ នឹងត្រូវអនុវត្តតាមបំណកស្រាយក្នុងករណីអនុវត្តតាមរបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលកំណត់ដោយច្បាប់ ឬ ករណីអនុវត្តតាមបញ្ញត្តិនៃកម្មសិទ្ធិអវិភាគ ដូចបានពន្យល់នៅក្នុងចំណុច **២.២.២.២**។ ដោយឡែក ទ្រព្យសម្បត្តិរបស់អនីតិសង្វាសណាម្ខាងដែលទទួលមរណភាព នឹងក្លាយជាកម្មវត្ថុនៃសន្តតិកម្ម។ យ៉ាងណាមិញ ភាគីអនីតិសង្វាសដែលនៅរស់មិនមែនជាសន្តតិជនរបស់ភាគីដែលទទួលមរណភាពឡើយ ដោយបញ្ញត្តិនេះអនុវត្តបានចំពោះតែអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ប៉ុណ្ណោះ។ ប៉ុន្តែ ភាគីនៃអនីតិសង្វាសដែលនៅរស់ អាចទទួលមរតកបាន បើភាគីនោះក្លាយខ្លួនជាអច្ច័យលាភី ឬ អាចដាក់ពាក្យសុំទៅតុលាការដើម្បីទទួលមរតកមួយផ្នែកបាន ដោយប្រើឋានៈជាជនមាននិស្ស័យពិសេសយោងតាមមាត្រា ១២៩៩ នៃក្រមរដ្ឋប្បវេណី។ ចំពោះកូនរបស់ភាគីនៃអនីតិសង្វាសវិញ អាចទទួលមរតកបាន លុះត្រាក្លាយខ្លួនជាអច្ច័យលាភី ឬ អាចក្លាយជាសន្តតិជនដែលមានលំដាប់ទី១[70]បាន បើឪពុកបានទទួលស្គាល់កូននោះ មានន័យថា ប្រសិនបើឪពុកនោះមិនបានទទួលស្គាល់កូននោះទេ កូនដែលកើតចេញពីចំណងអនីតិសង្វាសនេះ គឺមិនមានទំនាក់ទំនងរវាងឪពុកនិងកូននោះទេ ហើយកូននោះក៏មិនអាចក្លាយជាសន្តតិជនបានដែរ។ ប៉ុន្តែ កូននោះអាចដាក់បណ្ដឹងទាមទារឱ្យទទួលស្គាល់ក្រោយមរណភាពរបស់ឪពុកបាន ដើម្បីបង្កើតសិទ្ធិធ្វើសន្តតិកម្មចំពោះកូននោះបាន

---

[69] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, ២០០៩, *សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី១ : គន្ថីទី១-ទី៣*, ទំព័រ១៦៥។

[70] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៦ កថាខណ្ឌទី១។

ដែលបណ្តឹងនេះមានកម្រិតនៃអំឡុងពេលត្រឹមតែរយៈពេល ១ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់មតកជនដែលជាឪពុកនោះ។[71]

[71] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០០១ កថាខណ្ឌទី៥។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ប្តីប្រពន្ធសំដៅទៅលើស្ថានភាពពីរ គឺប្តីប្រពន្ធរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ឬ សហព័ទ្ធ និង ប្តីប្រពន្ធរៀបអាពាហ៍ពិពាហ៍មិនតាមផ្លូវច្បាប់ ឬ អនីតិសង្វាសជន។ ការណ៍ទាំងនេះនាំឱ្យការគ្រប់គ្រងទ្រព្យសម្បត្តិស្ថិតក្រោមរូបភាពខុសគ្នា ពោលគឺ សហព័ទ្ធធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនស្របតាមការកំណត់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងៗទៀត ដែលរួមមានប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមកិច្ចសន្យា និង ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់កំណត់។ ចំណែកឯ អនីតិសង្វាសជនធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនដោយអនុវត្តតាមបំណាកស្រាយពីរ គឺករណីអនុវត្តតាមរបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលកំណត់ដោយច្បាប់ និង ករណីអនុវត្តតាមបញ្ញត្តិអំពីកម្មសិទ្ធិអវិភាគ។

យ៉ាងណាមិញ ការសម្រេចចិត្តដែលចង់ក្លាយជាសហព័ទ្ធ ឬ អនីតិសង្វាសជន គឺជាសេរីភាពរបស់បុគ្គលដែលធានាដោយរដ្ឋធម្មនុញ្ញ និងឈរលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ដូចនេះត្រូវតែគោរពឆន្ទៈរបស់បុគ្គលនោះ។ ការសម្រេចចិត្តបែបណាមួយនោះ គឺត្រូវបានធ្វើដោយផ្អែកលើស្ថានភាពជាក់ស្តែងរបស់បុគ្គលម្នាក់ៗដែលបុគ្គលខ្លះមានលទ្ធភាព និងលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការបង្កើតអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយក្លាយជាសហព័ទ្ធ រីឯបុគ្គលខ្លះទៀតពុំមានលទ្ធភាព និងលក្ខខណ្ឌគ្រប់គ្រាន់ដែលអាចឱ្យច្បាប់អនុញ្ញាតបង្កើតអាពាហ៍-ពិពាហ៍តាមផ្លូវច្បាប់បានឡើយ ដូចជាករណីបុគ្គលស្រឡាញ់ភេទដូចគ្នា ជាអាទិ៍។

ទន្ទឹមនឹងគ្នានេះ ទោះរួមរស់ជាមួយគ្នាក្នុងស្ថានភាពជាសហព័ទ្ធក្តី អនីតិសង្វាសជនក្តី ការដែលអាចយល់ដឹងអំពីគុណសម្បត្តិ និងគុណវិបត្តិ នៃបែបបទក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនក៏មានសារសំខាន់ផងដែរ ដោយសារវាអាចផ្តល់ជាគំនិតក្នុងការជ្រើសរើសឱ្យស្របតាមស្ថានភាពជាក់ស្តែងរបស់ខ្លួនក្នុងអំឡុងពេលរស់នៅជាមួយគ្នា ក៏ដូចជាគំនិតក្នុងការបែងចែកទ្រព្យសម្បត្តិនោះវិញពេលបញ្ចប់ស្ថានភាពរស់នៅជាមួយគ្នា។ ក្នុងនោះ សហព័ទ្ធអាចសម្រេចចិត្តដោយសេរីអំពីជម្រើសក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួន ដែលការជ្រើសយកការគ្រប់គ្រងទ្រព្យសម្បត្តិតាមប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា គឺជាជម្រើសល្អ ដោយសារទាំងទ្រព្យសម្បត្តិរួមទាំងទ្រព្យសម្បត្តិដោយឡែក និងកាតព្វកិច្ចផ្សេងៗ បានចែងក្នុងកិច្ចសន្យា ដែលចងចំណងទៅលើភាគីនៃកិច្ចសន្យាពុំឱ្យបំពានបាន ប៉ុន្តែ នៅកម្ពុជា បទប្បញ្ញត្តិគ្រប់គ្រងលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធពុំទាន់មានគ្រប់គ្រាន់ និងសិក្សាស៊ីជម្រៅនៅឡើយ ជាពិសេសការកំណត់មិនទាន់ច្បាស់លាស់ពីទម្រង់ និងខ្លឹមសារនៃកិច្ចសន្យា។ ចំពោះអនីតិសង្វាសជន គឺពុំអាចជ្រើសរើសនូវបែបបទណាមួយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនឡើយ ហើយនៅពេលប្តឹងទាមទារឱ្យបែងចែកទ្រព្យសម្បត្តិ តុលាការមានឆន្ទានុសិទ្ធិក្នុងការសម្រេចឱ្យបែងចែកតាមបំណាកស្រាយណាមួយដូចបានបញ្ជាក់ខាងលើ។

# អនុសាសន៍

# អនុសាសន៍

តាមរយៈការសិក្សា និងពិភាក្សាលើឯកសារផ្សេងៗរួចមក ជម្រើសក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិត្រូវបាន បង្ហាញ ដែលផ្តល់លទ្ធភាពដល់សាធារណៈជនអាចជ្រើសរើសឱ្យស្របតាមគំនិត និងស្ថានភាពរបស់ខ្លួន។ ដូចនេះ ចំពោះសហព័ទ្ធម្ខាងជាអាជីវករ ឬ អ្នកជំនួញ ការជ្រើសរើសយកការគ្រប់គ្រងទ្រព្យសម្បត្តិតាមប្រព័ន្ធ ទ្រព្យសម្បត្តិតាមកិច្ចសន្យា គឺជាជម្រើសល្អ ដោយសារវាអាចការពារផលប្រយោជន៍សហព័ទ្ធម្ខាងទៀត នៅពេលសហព័ទ្ធនោះជួបស្ថានភាពក្ស័យធនក្នុងអាជីវកម្ម ឬ ជំនួញរបស់គាត់។ ម៉្យាងទៀត ចំពោះស្ថានភាពសហ-ព័ទ្ធម្ខាងជាស្ត្រីមេផ្ទះ ការជ្រើសយកការគ្រប់គ្រងទ្រព្យសម្បត្តិតាមប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា មិនមែនជាជម្រើសល្អទេ ព្រោះវាពុំផ្តល់អត្ថប្រយោជន៍ច្រើនសម្រាប់គាត់ដោយសារតែគាត់ពុំអាចចូលរួមក្នុងការបង្កើនទ្រព្យរួមបានច្រើន ហើយធ្វើឱ្យខាតបង់ប្រយោជន៍ជាមួយនីតិវិធីស្មុគស្មាញ ដូចនេះ ក្នុងករណីនេះ ការជ្រើសយកការគ្រប់គ្រងទ្រព្យសម្បត្តិតាមប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់ ជាជម្រើសល្អជាង។

ចំពោះស្ថានភាពអនីតិសង្វាសជន ការគ្រប់គ្រងទ្រព្យសម្បត្តិគឺពុំត្រូវបានកំណត់ និងការពារដោយច្បាប់ឡើយ ដែលការណ៍នេះសឱ្យឃើញពីភាពខុសគ្នារវាងអាពាហ៍ពិពាហ៍ស្របច្បាប់ និងអនីតិសង្វាស។ ដូចនេះ អនីតិសង្វាសជនណាដែលមានលទ្ធភាព និងបំពេញលក្ខខណ្ឌគ្រប់គ្រាន់នៃអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ គួរទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅស្ថាប័នមានសមត្ថកិច្ច ដើម្បីទទួលបាននូវការការពារពីច្បាប់។ យ៉ាងណាមិញ អនីតិ-សង្វាសនៅតែមានអត្ថិភាពក្នុងសង្គម ហើយភាគីរដ្ឋក៏ពុំអាចមិនយកចិត្តទុកលើបញ្ហានេះដែរ ដូចនេះគោលការណ៍ណែនាំរួមច្បាស់លាស់មួយគួរត្រូវបង្កើតពីសំណាក់ស្ថាប័នមានសមត្ថកិច្ចសម្រាប់គ្រប់គ្រងអនីតិសង្វាស ដោយធ្វើការកំណត់ពីលក្ខខណ្ឌ អានុភាព នៃអនីតិសង្វាស ព្រមទាំងមូលហេតុនិងអានុភាពនៃការបញ្ចប់អនីតិសង្វាសផងដែរ ជាមួយគ្នានេះ ក៏គួរជម្រុញឱ្យមានការឯកភាពគ្នាក្នុងការចូលរួមរបស់តុលាការទូទាំងប្រទេសដើម្បីដោះ-ស្រាយបញ្ហានៃអនីតិសង្វាស។

# ឯកសារយោង

# ឯកសារយោង

## ១- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត

- **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលនៅជាធរមាន**
  - រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
  - ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។
  - ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។
  - ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។
  - ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦។
  - ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
  - អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០។
  - ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ៩ សីហា ២០១៣។
- **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលបាននិរាករណ៍**
  - ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ, លេខ ៥៦ ក្រ, ២០ កក្កដា ១៩៨៩។

## ២- សៀវភៅ និងស្នាដៃនិពន្ធផ្សេងៗ

- គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ២០១០, *សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៧ : គន្ថីទី* ៥, រាជធានីភ្នំពេញ។
- គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ២០០៩, *សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី១ : គន្ថីទី ១-ទី* ៣, រាជធានីភ្នំពេញ។
- ក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៧, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ៣,* រាជធានីភ្នំពេញ។
- ក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៣, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ* ១, រាជធានីភ្នំពេញ។

- លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ២០១៧, *សៀវភៅជំនួយស្មារតី នីតិវិធីព្រហ្មទណ្ឌ និង នីតិគ្រួសារ*, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, រាជធានីភ្នំពេញ។
- ចក សម្បត្តិ, ២០១៤, *អនីតិសង្វាសជន*, រាជធានីភ្នំពេញ។
- សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០០៥, *សទ្ទានុក្រមបារាំង-ខ្មែរនៃពាក្យច្បាប់*។
- អេង សុត, ១៩៦៧, *ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុង ក្រមរដ្ឋប្បវេណី*, ក្រសួងយុត្តិធម៌។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឈ្មោះ.......................................ភេទ ប្រុស អាយុ..........ថ្ងៃ ខែ ឆ្នាំកំណើត......................ជាប្តី ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ.............ផ្លូវលេខ.......... ភូមិ...............................ឃុំ សង្កាត់.............................ក្រុង ស្រុក ខណ្ឌ..............................រាជធានី ខេត្ត...................................។

ឈ្មោះ.......................................ភេទ ស្រី អាយុ...........ថ្ងៃ ខែ ឆ្នាំកំណើត.................................. ជាប្រពន្ធ ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ..........ផ្លូវលេខ ..........ភូមិ.........................ឃុំ សង្កាត់.........................ក្រុង ស្រុក ខណ្ឌ..........................រាជធានី ខេត្ត...................................។

ឈ្មោះរបស់អ្នកតំណាង..........................................ភេទ.............អាយុ.............ថ្ងៃ ខែ ឆ្នាំកំណើត ................................អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ..............ផ្លូវលេខ...............ភូមិ............................ឃុំ សង្កាត់.....................ក្រុង ស្រុក ខណ្ឌ....................រាជធានី ខេត្ត...................................។

## សូមគោរពជូន

## ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**កម្មវត្ថុ ៖** សំណើសុំចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជី : ..........................................................................................។

- មូលហេតុ : .........................................................................................................។

- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ : ...........................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើដោយក្តីអនុគ្រោះ។

ថ្ងៃ.....................................ខែ.............ឆ្នាំ......................ព.ស...............

ធ្វើនៅ............................ថ្ងៃទី..........ខែ............ឆ្នាំ............

**ស្នាមម្រាមដៃ**

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

# ឯកសារភ្ជាប់

## ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-សំបុត្រអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍

-វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ ) ក្នុងករណីដែលកិច្ចសន្យានេះពាក់ព័ន្ធនិងបញ្ហាដីធ្លី

-លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)

-អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

# ឧបសម្ព័ន្ធទី២

Ny-Revised by Rathen

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

រឿងក្តីរដ្ឋប្បវេណី

លេខ:៣៥៦/២១.៧.០៩

**សាលាឧទ្ធរណ៍ភ្នំពេញ**

សាលដីកា

**នាមប្រជារាស្ត្រខ្មែរ**

លេខ :០២ (គ) / ២៦.១១.០៩

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី២៦-១១-២០០៩ វេលាម៉ោង១៤:០០រសៀល ។

សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

១[redacted] ជាប្រធានក្រុមប្រឹក្សា

២-[redacted] ចៅក្រមប្រឹក្សា

៣-[redacted] ចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

[redacted]

ក្រឡាបញ្ជី

[redacted]

-ដើមចោទឈ្មោះ[redacted] ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរចុងភៅ ទីលំនៅ[redacted] ឪពុកឈ្មោះ[redacted](ស) ម្តាយឈ្មោះ[redacted](រ) ប្រពន្ធឈ្មោះ[redacted] មានកូន០១នាក់ ។

-ចុងចម្លើយឈ្មោះ[redacted] ភេទស្រី អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅ[redacted] ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ[redacted](រ) ប្តីឈ្មោះ[redacted]មានកូន០១នាក់

អង្គហេតុ និងចំណុចវិវាទ

ឈ្មោះ[redacted] បានរៀបការជាមួយឈ្មោះ[redacted] ជាចុងចម្លើយនៅឆ្នាំ២០០៤ ពុំបានចុះសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ទេ ហើយបានរស់នៅជាមួយគ្នារហូតមកដល់ថ្ងៃនេះមានកូនស្រី០១នាក់ ឈ្មោះ[redacted] ដោយការរស់នៅមិនចុះសំរុងចេះតែទំនាស់គ្នាជាប្រចាំ ជាហេតុធ្វើអោយអស់មនោសញ្ចេតនាជាប្តីប្រពន្ធ ។

១-ការអះអាងរបស់ដើមចោទ : ខ្លួនមិនអាចរួមរស់នៅជាមួយគ្នាបានទៀតទេ កូនសុខចិត្តប្រគល់ឱ្យចុងចម្លើយ គ្រប់គ្រង ខ្លួនរៀបការឆ្នាំ ២០០៤ ទ្រព្យសម្បត្តិរួមមានដីលក់អស់ហើយ ។ ដីនេះពុំមានពាក់ព័ន្ធជាមួយខ្លួនទេ មានដីពីរកន្លែងនៅ

ខេត្តព្រះវិហារ តែខ្លួនមិនស្គាល់ដីនោះ។ ដីនៅសៀមរាប និង ដីនៅខេត្តព្រះវិហារលក់ តែយកលុយសងគេអស់ហើយ នៅសល់ដីពីរកន្លែងនៅព្រះវិហារ។សំណូមពរសុំបែងចែកទ្រព្យរួមស្មើគ្នា ឯប្រាក់អាហារកិច្ចចិញ្ចឹមកូនពុំមានលទ្ធភាព តាមសំណូមពរចុងចម្លើយទេ។ ដីពីរកន្លែងនៅព្រះវិហារទំហំ២៧ម គុណ ៥០ម និង ៣០ម គុណ ១០០ម ជាទ្រព្យរួម។

២-ការអះអាងរបស់ចុងចម្លើយ : ខ្លួនប្តឹងឧទ្ធរណ៍សុំបដិសេធសាលក្រមថ្នាក់ក្រោម មូលហេតុដីដែលតុលាការចែកជាដីម្តាយខ្លួនទិញហើយផ្ទេរសិទ្ធិឱ្យខ្លួន។ដីនោះមានបីកន្លែងជាទ្រព្យរួម សព្វថ្ងៃលក់នៅសល់ពីរកន្លែង។ ខ្លួនសុំទាមទារអាហារកិច្ចចិញ្ចឹមកូន២០០ដុល្លា និងឯកភាពបែងចែកដីពីរកន្លែងជាទ្រព្យរួមជាពីរចំណែកស្មើគ្នា។

## សំអាងហេតុ

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩ របស់ឈ្មោ[redacted]ប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ២២(គ) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តសៀមរាប ត្រង់ចំណុច នៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន យោងមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-តាមសេចក្តីថ្លែងការណ៍របស់ចុងចម្លើយ (ដើមបណ្តឹងឧទ្ធរណ៍) នាពេលទាញហេតុផលដោយផ្ទាល់មាត់ នៅសាលាឧទ្ធរណ៍ថា ខ្លួនសុំប្តឹងឱ្យលុបខ្លឹមសារ នៃសាលក្រមត្រង់ចំណុចទី៤ -គ ព្រោះដីនោះបានលក់ឱ្យគេយូរហើយ និងសុំឱ្យដើមចោទបង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនចំនួន២០០ដុល្លា ក្នុង១ខែ។ ចំពោះដីពីរកន្លែងទៀត ត្រង់ចំណុចទី៤-ក និង ទី៤-ខ នៃសាលក្រមខ្លួនទទួលស្គាល់ថា ជាទ្រព្យសម្បត្តិរួម និង ឯកភាពបែងចែកជាពីរចំណែកស្មើគ្នា។ តាមការអះអាងលើចំណុចទី៤-គ គប្បីតុលាការទទួលយកមកពិចារណាឡើងវិញ ព្រោះគ្មានឯកសារបញ្ជាក់ការកាន់កាប់ដីនោះនៅក្នុងសំណុំរឿងទេ។

៣-ដើមចោទពុំមានការតវ៉ា នឹង ការអះអាងរបស់ចុងចម្លើយត្រង់ចំណុចទី៤-គទេ ។ ខ្លួនពុំស្គាល់ទីតាំងដីនោះទេ ។ ខ្លួនសុំឱ្យ បែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា។ ដោយឡែក ប្រាក់អាហារកិច្ចចិញ្ចឹមកូនខ្លួនគ្មានសមត្ថភាពផ្គត់ផ្គង់ទេ។ ខ្លួនរកប្រាក់ចំណូលបានប្រហែល១០០ដុល្លាក្នុង១ខែ។

៤-តំណាងមហាអយ្យការសន្និដ្ឋានថា ចំពោះទ្រព្យសម្បត្តិរួម សូមតុលាការសម្រេចតាមច្បាប់។ ចំពោះប្រាក់អាហារកិច្ច ឪពុកម្តាយមានកាតព្វកិច្ចចិញ្ចឹមកូន ហេតុនេះ សុំតុលាការពិនិត្យ ពិចារណាតាមច្បាប់។

៥-សាលក្រមរដ្ឋប្បវេណីលេខ ២២(គ) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តសៀមរាប បានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តំកល់សាលក្រមខាងលើទុកជាបានការ លើកលែងតែចំណុចទី៤-គ ដែលត្រូវកែប្រែដូចការយល់ឃើញខាងលើ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩ របស់ឈ្មោះ[redacted]ដើម្បីជំនុំជំរះតាមច្បាប់។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ២២(គ) ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តសៀមរាប ទុកជាបានការ លើកលែងតែចំណុចទី៤-គ ដែលត្រូវសម្រេចលុបចោល។ ចំណុចដទៃទៀតនៅរក្សាទុកដដែល។

៣-បង្គាប់ឱ្យដើមចោទបង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនចំនួន១០ម៉ឺនរៀល(ដប់ម៉ឺនរៀល) ក្នុង១ខែ ឱ្យចុងចម្លើយ។

៤-ប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ជាបន្ទុករបស់ដើមចោទ។

៥-សាលដីកានេះទាញហេតុផលដោយផ្ទាល់មាត់ចំពោះមុខគូភាគី ប្រកាសជាសាធារណៈនៅថ្ងៃទី២៦-១១-២០០៩។

គូភាគីមានសិទ្ធិ ប្តឹងសាទុក្ខក្នុងរយៈពេល១ខែគិតចាប់ពីថ្ងៃបានទទួលការបញ្ជូន សាលដីកានេះ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| [redacted] | [redacted] | [redacted] |